# ការដាំក្រុមជំនុំដែលមានសុខភាពល្អ

## សេចក្តីណែនាំសម្រាប់អ្នកដឹកនាំសិក្ខាសាលា

### សេចក្តីអត្ថាធិប្បាយ

សិក្ខាសាលានេះជួយអ្នកដឹកនាំឲ្យឆ្លុះបញ្ចាំងអំពីការងារ និងសមត្ថភាព ដែលមានប្រយោជន៍ចំពោះការដាំក្រុមជំនុំដែលមានសុខភាពល្អ។ វគ្គនេះរួមមានមេរៀនដូចជាៈ មូលដ្ឋានព្រះគម្ពីរសម្រាប់ការដាំក្រុមជំនុំ សណ្ឋាន និងគ្រួសាររបស់អ្នកដាំក្រុមជំនុំ ជំហានក្នុងការដាំក្រុមជំនុំ គំរូសម្រាប់ការដាំក្រុមជំនុំ និងលក្ខណៈក្រុមជំនុំដែលមានសុខភាពល្អ។

multiplication network

*more churches, stronger churches*

Received May 26, 2014

ការណែនាំរបស់អ្នកដឹកនាំ|

គោលបំណងរបស់ THE MULTIPLICATION NETWORK

ការដាំក្រុមជំនុំដែលមានសុខភាពល្អ ជាវគ្គសិក្ខាសាលាដែលផ្អែកលើទៅលើសៀវភៅមួយដែលមានចំណងជើងតែមួយ និងត្រូវបានសរសេរនៅអាមេរិក ដោយអ្នកនិពន្ធចំនួនម្ភៃពីររូបមកពីដប់មួយប្រទេស។

នៅក្នុងសៀវភៅនេះ មានសំណួរឆ្លុះបញ្ចាំង និងសកម្មភាព។ សំណួរនិងសកម្មភាពទាំងនេះ អាចត្រូវបានធ្វើឡើងជាលក្ខណៈផ្ទាល់ខ្លួន ជាគូ ឬជាក្រុមតូច។ ចូររើសសំណួរ និងសកម្មភាពស័ក្តិសមបំផុតសម្រាប់សិក្ខាកាមរបស់លោកអ្នក ដើម្បីប្រើក្នុងពេលធ្វើសិក្ខាសាលា និងត្រូវសុំសិក្ខាកាមឲ្យត្រឡប់ទៅកាន់សំណួរមួយទៀតដោយខ្លួនឯង បន្ទាប់ពីចប់សិក្ខាសាលា។

ប្រសិនបើលោកអ្នកត្រូវការជំនួយជួយជាសិក្ខាសាលា សូមទាក់ទងតំណាងអង្គការ THE MULTIPLICATION NETWORK នៅក្នុងប្រទេសរបស់លោកអ្នក។ អាសយដ្ឋានទំនាក់ទំនងរបស់ពួកគេ អាចរកបាននៅលើគេហទំព័ររបស់យើង។

ធនធានដែលអ្នកដឹកនាំសិក្ខាសាលាត្រូវមានៈ

១, សៀវភៅមេរៀនរបស់អ្នកដឹកនាំ

២, សៀវភៅមេរៀនរបស់សិក្ខាកាម

៣, ការបញ្ចាំងរូបភាពព៌ណ ឬ PowerPoint slides (អាចរកបានជា CD ឬតាមរយៈគេហទំព័ររបស់យើង)

៤, ជំនួយពីគ្រូហ្វឹកហ្វឺន MNM (ចូលទៅកាន់គេហទំព័ររបស់យើង www.multiplicationnetwork.org

របៀបប្រើការណែនាំនេះ|

ការណែនាំរបស់គ្រូហ្វឹកហ្វឺននឹងបង្ហាញលោកអ្នកមួយទំព័រម្តងៗ អំពីរបៀបដឹកនាំសិក្ខាសាលានេះ។ ជាការសំខាន់ណាស់ ដែលត្រូវចាំថា គ្រូហ្វឹកហ្វឺនម្នាក់ៗមានសេរីភាពបន្ថែមមេរៀន ដែលផ្អែកទៅលើបទពិសោធន៍របស់ពួកគេ ការប្រើប្រាស់រូបភាពពន្យល់ និងរឿងខ្លីៗរបស់ពួកគេ។ នៅខាងឆ្វេងនៃទំព័រនីមួយៗ លោកអ្នកនឹងឃើញយោបល់សម្រាប់គ្រូហ្វឹកហ្វឺន និង PowerPoint slides ដែលប្រើសម្រាប់ទំព័រនោះ។ ផ្នែកដ៏សំខាន់នៃទំព័រនីមួយៗ មានទំព័រដូចដែលបានបង្ហាញនៅក្នុងផ្ទាំងកម្រងឯកសារមេរៀន រួមមានទាំងចម្លើយសម្រាប់គ្រូហ្វឹកហ្វឺន។ ប្រហែលជាគ្មានពេលគ្រប់គ្រាន់សម្រាប់សកម្មភាពឆ្លុះបញ្ចាំង រួមបញ្ចូលទាំងសៀវភៅមេរៀនទាំងអស់នោះទេ។ ចូរប្រើប្រាស់មេរៀនណាមួយដែលស័ក្តិសមបំផុតទៅនឹងក្រុមរបស់លោកអ្នក រួចលើកទឹកចិត្តសិក្ខាកាមឲ្យធ្វើមេរៀនមួយទៀត ដោយខ្លួនឯង ក្រោយពីវគ្គហ្វឹកហ្វឺននេះ។

កាលវិភាគដាក់ជូន|

យើងបានដាក់ជូនកាលវិភាគសម្រាប់សិក្ខាសាលារយៈពេលមួយថ្ងៃ។ ទោះជាយ៉ាងណាក្តី យើងសូមលើកទឹកចិត្តឲ្យលោកអ្នករៀបចំកាលវិភាគទៅតាមអ្វីដែលប្រសើរបំផុតសម្រាប់លោកអ្នក និងសិក្ខាកាម។ លោកអ្នកក៏អាចធ្វើសិក្ខាសាលារយៈពេលបួនសប្តាហ៍ (មួយសប្តាហ៍មួយវគ្គ) ឬនៅរាល់ព្រឹកថ្ងៃសុក្រ និងថ្ងៃសៅរ៍ ដើម្បីកាត់បន្ថយចំណាយ។ វគ្គនីមួយៗត្រូវបានគេរៀបចំសម្រាប់រយៈពេលមួយម៉ោងកន្លះ។ សូមលៃពេលល្មមឲ្យសិក្ខាកាមបំពេញក្រដាសវាយតម្លៃ។ ប្រសិនបើអាច សូមថតរូប digital សិក្ខាសាលារបស់លោកអ្នកមួយសន្លឹកផ្ញើមកកាន់ Multiplication Network រួមជាមួយនឹងរបាយការណ៍របស់លោកអ្នកអំពីព្រឹត្តិការណ៍នោះ (សូមចូលទៅកាន់គេហទំព័ររបស់យើងសម្រាប់ទម្រង់របាយការណ៍ ឬនៅទំព័រទី៥១ នៃសៀវភៅមេរៀននេះសម្រាប់ព័ត៌មានដែលយើងចង់ឲ្យលោកអ្នកផ្ញើឲ្យយើង)។

សម្ភារៈសិក្ខាសាលា|

គោលបំណងរបស់យើង គឺឲ្យសិក្ខាសាលានេះអាចធ្វើបានសម្រាប់អ្នកដឹកនាំឲ្យបានច្រើនតាមដែលអាចធ្វើបានដោយចំណាយថវិកាតិចតួច ឬមិនចំណាយទាល់តែសោះ។ លោកអ្នកអាចថតចម្លងនៅក្នុងស្រុកចំពោះសៀវភៅមេរៀនរបស់សិក្ខាកាម ហើយសហការណ៍ជាមួយក្រុមជំនុំដែលពាក់ព័ន្ធក្នុងការរៀបចំភេសជ្ជៈ និងអាហារផ្សេងៗ។

លោកអ្នកអាចធ្វើក្របផ្សេងពីនេះដោយសេរី ជាមួយនឹងការតុបតែងរចនាឲ្យកាន់តែស័ក្តិសមទៅនឹងបរិបទនៅក្នុងសៀវភៅមេរៀនដែលត្រូវប្រើនេះ។

MULTIPLICATION NETWORK
ខគម្ពីរយោងទាំងអស់បានមកពីសំណៅ New International Version សិទ្ធិថតចម្លង 1973, 1978, 1984 ។

## មាតិកា

មេរៀនទី១|

ហេតុអ្វីត្រូវដាំក្រុមជំនុំដែលមានសុខភាពល្អ? .......................... 3

មេរៀនទី២|

តើនរណាខ្លះត្រូវដាំក្រុមជំនុំ? .......................................... 11

មេរៀនទី៣|

តើក្រុមជំនុំដែលយើងនឹងបង្កើតនោះមានលក្ខណៈដូចម្តេច? ....... 23

មេរៀនទី៤ |

តើជំហានអ្វីខ្លះដែលយើងត្រូវឈានដើម្បីដាំក្រុមជំនុំមួយ? .......... 37

វិញ្ញាបនប័ត្រ ............................................................ 53

| **កាលវិភាគគំរូ** | |
|---|---|
| **ចុះឈ្មោះ និងស្វាគមន៍** | |
| **ម៉ោងថ្វាយបង្គំ** | ៣០ នាទី |
| **វគ្គ១** | ៩០ នាទី |
| **វគ្គ២** | ៩០ នាទី |
| សម្រាកខ្លី | |
| **វគ្គ៣** | ៩០ នាទី |
| **វគ្គ៤** | ៩០ នាទី |
| វគ្គសំណួរចម្លើយ ការវាយតម្លៃ បិទវគ្គ | |

មេរៀនទី១ |

# ហេតុអ្វីត្រូវដាំក្រុមជំនុំដែលមានសុខភាពល្អ?

*«...បានស្គាល់ពីប្រាជ្ញានៃព្រះដ៏មានជាច្រើនយ៉ាងណាស់ ដោយសារពួកជំនុំ»*
*អេភេសូរ ៣:១០។*

លោកអ្នកអាចសម្គាល់ថាដ្យាក្រាមដែលមានកូឡោនបួនសៀវភៅមេរៀនរបស់សិស្សតំណាងឲ្យមូលដ្ឋាននីមួយៗក្នុងចំណោមគ្រឹះទាំងបួនដែលនឹងត្រូវបានពន្យល់នៅក្នុងមេរៀនទី១។

## គោលដៅ:

គោលដៅមេរៀនផ្ដល់ជូននូវគ្រឹះស្របតាមព្រះគម្ពីរ ស្របតាមទេវសាស្ត្រ ស្របតាមបេសកកម្ម សម្រាប់ការដាំក្រុមជំនុំថ្មីមួយ។ យើងឆ្លើយតបទៅនឹងកម្មវត្ថុទូទៅមួយចំនួន ព្រមទាំងផ្ដល់ជូននូវនិមិត្តទូលំទូលាយ សម្រាប់បង្កើតសហគមន៍ជំនឿថ្មីមួយ។

**សេចក្ដីផ្ដើម** | មូលដ្ឋានគ្រឹះ




## និយមន័យ:

នៅជំពូកទីពីរ នៅក្នុងការដាំក្រុមជំនុំដែលមានសុខភាពល្អនេះ បណ្ឌិត ឆាល វ៉ាន់អ៊ីកហ្គិន (Charles VanEngen) ផ្ដល់ជូននូវទ្រឹស្ដីខាងក្រោមអំពីមូលដ្ឋានតាមព្រះគម្ពីរ សម្រាប់ការដាំក្រុមជំនុំ។

*«ការយល់ដឹងស្របតាមគម្ពីរសម្រាប់ការដាំក្រុមជំនុំដែលមានសុខភាពល្អ ដែលផ្អែកលើបេសកកម្មនៃសេចក្ដីស្រឡាញ់ និងសេចក្ដីមេត្តាករុណារបស់ព្រះត្រីឯក (ព្រះរាជបេសកកម្ម) ដែលសព្វព្រះហឫទ័យឲ្យបុរសស្ត្រីទាំងអស់បានត្រឡប់ជាសិស្សរបស់ព្រះយេស៊ូគ្រិស្ត និងជាសមាជិកក្រុមជំនុំដែលទទួលខុសត្រូវ ជារូបកាយរបស់ព្រះគ្រិស្ត ហើយក្រុមជំនុំរបស់ទ្រង់នេះហើយជាសញ្ញានៃការមកដល់នៃព្រះរាជ្យរបស់ព្រះសម្រាប់ជាការសរសើរដល់សិរីរុងរឿងរបស់ព្រះអង្គ»។*

**ចូរឆ្លើយសំណួរខាងក្រោមអំពីនិយមន័យខាងលើ**

តើចរិតលក្ខណៈរបស់ព្រះដែលបានបង្ហាញនៅក្នុងនិយមន័យនេះមានអ្វីខ្លះ?
**១. សេចក្តីស្រឡាញ់**
**២. សេចក្តីមេត្តាករុណា**

យោងតាមនិយមន័យ តើព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យមានអ្វី?
**១. សិស្សរបស់ព្រះយេស៊ូគ្រិស្ត**
**២. សមាជិកក្រុមជំនុំដែលទទួលខុសត្រូវ**

តើក្រុមជំនុំដែលកើតឡើង ជាសញ្ញានៃអ្វី?
**ការមកដល់នៃព្រះរាជ្យរបស់ព្រះ**

---

ហេតុអ្វីបានជាយើងត្រូវដាំក្រុមជំនុំ?
**សម្រាប់ជាការសរសើរដល់សិរីរុងរឿងរបស់ព្រះអង្គ**

---

**សកម្មភាពផ្តើមៈ**

ចូរសុំឲ្យសិក្ខាកាមផ្តល់ជូនលោកអ្នកនូវហេតុផលមួយចំនួនសម្រាប់ការដាំក្រុមជំនុំថ្មី។ ចូរឲ្យសិក្ខាកាមស្តាប់ផ្ទៀងផ្ទាត់មើល ថាតើមានហេតុផលណាមួយបានបង្ហាញក្នុងមេរៀននេះឬទេ។

**មូលដ្ឋានគ្រឹះស្របតាមព្រះគម្ពីរ**

មានហេតុផលប្រាំស្របតាមព្រះគម្ពីរ សម្រាប់ការដាំក្រុមជំនុំដែលមានសុខភាពល្អកាន់តែច្រើនៈ

១. **ព្រោះព្រះជាម្ចាស់ដ៏ជាព្រះវរបិតាស្វែងរកអ្នកបាត់បង់**
ខគម្ពីរគន្លឹះ | លោកុប្បត្តិ ៣:៩; ទំនុកតម្កើង ២៣; លូកា ១៤:១៥-២៤

២. **ព្រោះសេចក្តីស្រឡាញ់របស់ព្រះគ្រិស្តជំរុញយើង**
ខគម្ពីរគន្លឹះ | ២កូរិនថូស ៥:១៤-២០; ម៉ាថាយ ១៨:២០; យ៉ូហាន ១៤:២៣

៣. **ព្រោះព្រះវិញ្ញាណបរិសុទ្ធត្រូវបានចាត់ឲ្យមកសម្រាប់មនុស្សទាំងអស់**
ខគម្ពីរគន្លឹះ | កិច្ចការ ២:៩-១១; និង ១៣:២-៥ និង ១:៨

៤. **ព្រោះក្រុមជំនុំនៅតាមតំបន់ជាមែកធាងនៃព្រះរាជ្យរបស់ព្រះ**
ខគម្ពីរគន្លឹះ | ១ពេត្រុស ២:៥; ៩-១០, ១២; កូឡុស ១:១៣-២៣ និង រ៉ូម ១២

៥. **ព្រោះការដាំក្រុមជំនុំថ្មីថ្វាយសិរីរុងរឿងដល់ព្រះ**
ខគម្ពីរគន្លឹះ | អេភេសូរ ១:១-១៤; វិវរណៈ ៧:៩-១២

## មូលដ្ឋានគ្រឹះស្របតាមព្រះគម្ពីរ

ស្ទួត មើរី (Stuart Murry) សង្ខេបមូលដ្ឋានទេវសាស្ត្រនៅក្នុងសៀវភៅរបស់គាត់ ដែលមានចំណងជើងថា «ការចាក់គ្រឹះ» ថា ទាំងការលូតលាស់របស់ក្រុមជំនុំ និងការដាំក្រុមជំនុំថ្មី មានមូលដ្ឋានផ្អែកលើគោលការណ៍យ៉ាងហោចណាស់ ចំនួនបីៈ

### ១. ការចាប់កំណើត

ព្រះជាម្ចាស់យកកំណើតក្នុងព្រះយេស៊ូ ដើម្បីបង្ហាញអង្គទ្រង់ឲ្យមនុស្សជាតិស្គាល់ច្បាស់ជាយ៉ាងណា ក្រុមជំនុំក៏ត្រូវយកកំណើតនៅក្នុងសហគមន៍មួយពិតប្រាកដដែលមានសេចក្តីត្រូវការ ហើយនាំយករាជសារនៃដំណឹងល្អទាំងមូលជាយ៉ាងនោះដែរ។ ក្រុមជំនុំជារូបកាយរបស់ព្រះគ្រិស្ត ស្ថិតនៅកន្លែងមួយពិតប្រាកដ ដែលបង្ហាញខ្លួនឲ្យមនុស្សស្គាល់ច្បាស់ ដើម្បីឈោងចាប់ពួកគេដោយដំណឹងល្អអំពីជីវិតនៅក្នុងព្រះគ្រិស្ត។

**ខគម្ពីរគន្លឹះ ៖** | ភីលីព ២:៥-៨
យ៉ូហាន ១:១, ១:១៤

*«នៅក្នុងប្រវត្តិសាស្ត្រ មានមនុស្សច្រើនណាស់ដែលចង់ក្លាយដូចជាព្រះ ប៉ុន្តែ មានតែព្រះមួយអង្គគត់ ដែលបានក្លាយជាមនុស្ស»។*

### ២. ព្រះរាជបេសកកម្ម (បេសកកម្មរបស់ព្រះ)

ព្រះនៃព្រះគម្ពីរ ជាព្រះដែលជានិច្ចកាល ស្វែងរកអ្នកបាត់បង់ និងអ្នកដែលមានសេចក្តីត្រូវការ ដើម្បីនាំពួកគេមកកាន់សេចក្តីសង្គ្រោះ និងការផ្លាស់ប្រែ។ ក្នុងរបៀបតែមួយនេះ ក្រុមជំនុំត្រូវយកគំរូតាមព្រះនៅក្នុងបេសកកម្មរបស់ខ្លួន សម្រាប់ការបង្កើតសិស្ស បំផ្លាស់បំប្រែសហគមន៍ និងជាភ្នាក់ងារតំណាងឲ្យព្រះជាម្ចាស់សម្រាប់ការផ្លាស់ប្រែ ដោយមានព្រះវត្តមានរបស់ព្រះអង្គគង់នៅជាស្រេច ធ្វើសកម្មភាពក្នុងពិភពលោកនេះ។

**ខគម្ពីរគន្លឹះ ៖** | យ៉ូហាន ៣:១៦, ម៉ាថាយ ២៨:១៨-២០,
ម៉ាកុស ១៦:១៥-១៦, លូកា ២៤:៤៦-៤៩

*«ក្រុមជំនុំកើតដោយសារបេសកកម្ម ដូចជាភ្លើងកើតដោយសារការបង្កាត់»។*
*ដោយ អ៊ីមែល ប្រាននឺរ*

### ៣. ព្រះរាជ្យរបស់ព្រះជាម្ចាស់

ក្រុមជំនុំប្រកាស និងបង្ហាញអំពីអ្វី ដែលព្រះយេស៊ូបានប្រកាស និងបានបង្ហាញ គឺអំពីការមកដល់នៃព្រះរាជ្យរបស់ព្រះ! ក្រុមជំនុំបង្ហាញ ផ្តល់សញ្ញា យកកំណើត និងបង្រៀនអំពីព្រះរាជ្យរបស់ព្រះ ដែលល្អ សុចរិត និងគ្រប់គ្រងលើអ្វីៗសព្វសារពើដែលជាស្នាព្រះហស្តរបស់ព្រះអង្គ។

**ខគម្ពីរគន្លឹះ ៖** | ១ពេត្រុស ២:៩-១២
កូឡុស ១:១៣

*«ចូរស្វែងរកនគរព្រះ និងសេចក្តីសុចរិតរបស់ព្រះអង្គជាមុន នោះគ្រប់អ្វីៗទាំងអស់នឹងបន្ថែមឲ្យអ្នក»* ដោយព្រះយេស៊ូវគ្រិស្ត (ម៉ាថាយ ៦:៣៣)

១. អ្វីដែល**ជា**ក្រុមជំនុំ
ខ្លឹម និងលក្ខណៈរបស់ក្រុមជំនុំកើតចេញពីព្រះជាម្ចាស់ និងបានកំណត់ទុកដោយព្រះអង្គផ្ទាល់។ ព្រះជាម្ចាស់ជាអ្នកប្រទាន និងជាអ្នកបង្កើតក្រុមជំនុំ។ នោះជាអ្វីដែលព្រះជាម្ចាស់ប្រទានឲ្យយើងទុកជាអំណោយ (សហគមន៍ដែលបានកើតដោយសារព្រះគុណ) ហើយក៏ជាកិច្ចការរបស់យើងដែរ ដែលត្រូវរស់នៅជាក្រុមជំនុំ។ ចំណែកនៃការងារបរិសុទ្ធនោះ គឺការដាំក្រុមជំនុំថ្មី។

២. អ្វីដែលក្រុមជំនុំ**ធ្វើ**
ចរិតរបស់ក្រុមជំនុំបង្កើតអ្វីដែលក្រុមជំនុំធ្វើ គឺប្រកាស បម្រើ និងធ្វើព័ន្ធកិច្ច។ ក្រុមជំនុំជាប្រជារាស្ត្ររបស់ព្រះដែលមានបេសកកម្ម។ ក្រុមជំនុំធ្វើសកម្មភាពទៅតាមចរិតរបស់ខ្លួន។ គឺដូចជាបក្សីដែលហើរ ព្រោះវាជាបក្សី។ ក្រុមជំនុំធ្វើបេសកកម្ម ដោយព្រោះនោះជាក្រុមជំនុំ គឺមនុស្សជួបជុំគ្នា«ប្រកាស សរសើរតម្កើងដល់ព្រះអង្គ ដែលបានត្រាស់ហៅពួកគេចេញពីសេចក្ដីងងឹតចូលមកក្នុងពន្លឺដ៏អស្ចារ្យ...» ១ពេត្រុស ២:៩។

៣. ក្រុមជំនុំ**ចាត់ចែង**អ្វីដែលត្រូវធ្វើ
នៅពេលដែលក្រុមជំនុំយល់អំពីចរិត និងគោលបំណងរបស់ខ្លួន ក្រុមជំនុំនឹងរៀបចំរចនាសម្ព័ន្ធអង្គភាពរបស់ខ្លួន នៅជុំវិញបេសកកម្មរបស់ខ្លួន។ ការឃោងចាប់អ្នកបាត់បង់ មិនមែនជាអ្វីដែលបានបន្ថែមទៅឲ្យក្រុមជំនុំក្នុងតំបន់នោះទេ ប៉ុន្តែជាផ្នែកមួយនៃចរិតរបស់ក្រុមជំនុំក្នុងតំបន់។ ក្រុមជំនុំរៀបចំជីវិតរបស់ខ្លួន ដើម្បីឃោងចាប់អ្នកបាត់បង់ដោយដំណឹងល្អ។

## មូលដ្ឋានគ្រឹះស្របតាមបេសកកម្ម

លោកហ្វ្រែ្គវ៉ាន់ហ្គែលឌ័រ នៅក្នុងសៀវភៅរបស់លោក ដែលមានចំណងជើងថា «ខ្លឹមរបស់ក្រុមជំនុំ» លោកដៅចំណាំចំណុចសំខាន់បីដែលពាក់ព័ន្ធទៅនឹងក្រុមជំនុំ និងបេសកកម្មរបស់ក្រុមជំនុំ។

## ក្រុមជំនុំ ជាក្រុមជំនុំដែលបំពេញតាមបេសកកម្មរបស់ខ្លួន និងចាត់ចែងអ្វីដែលត្រូវធ្វើ |

១. អ្វីដែល**ជា**ក្រុមជំនុំ (ខ្លឹម/លក្ខណៈរបស់ក្រុមជំនុំ) ១ពេត្រុស ២:៩-១០; អេភេសូរ ៤:២៤; ១កូរិនថូស ១២:១២-១៣

ក្រុមជំនុំ ជាសហគមន៍មួយដែលព្រះជាម្ចាស់បង្កើតឡើង ធ្វើជាប្រជារាស្ត្ររបស់ព្រះអង្គ ហើយក៏ជាភ្នាក់ងារនៃការបំផ្លាស់បំប្រែដែរ នៅក្នុងសង្គម និងអ្វីៗសព្វសារពើរ។ ក្រុមជំនុំជាមនុស្សជាតិថ្មីដែលបានកើតក្នុងព្រះយេស៊ូគ្រិស្ត មានលក្ខណៈដូចជាព្រះនៅក្នុងសេចក្តីសុចរិត និងភាពបរិសុទ្ធពិតប្រាកដ។ ក្រុមជំនុំជារូបកាយរបស់ព្រះគ្រិស្ត ដែលបានភ្ជាប់មកក្នុងគ្រួសារតែមួយ ដោយព្រះវិញ្ញាណបរិសុទ្ធ។

២. អ្វីដែលក្រុមជំនុំ**ធ្វើ** (តួនាទី/គោលបំណង) ១ពេត្រុស ២:៩-១០, ១២

អ្វីដែលក្រុមជំនុំធ្វើ អាស្រ័យលើក្រុមជំនុំជាអ្នកណាពិតប្រាកដ។ ក្រុមជំនុំប្រកាសអំពីព្រះរាជ្យរបស់ព្រះនៅក្នុងព្រះយេស៊ូគ្រិស្ត រស់នៅតំណាងឲ្យដំណឹងល្អនៅក្នុងបរិបទជាក់លាក់ និងចូលរួមនៅក្នុងបេសកកម្មរបស់ព្រះ។ នៅទីនេះ យើងឃើញថា ស្ថាបនកម្មគ្រិស្តបរិស័ទបន្តពីដៃមួយទៅដៃមួយទៅតាមតួនាទីរបស់ខ្លួន ក្នុងការប្រកាស បម្រើ និងធ្វើព័ន្ធកិច្ច។ ការនោះរំឭកយើងថា ក្រុមជំនុំជាប្រជារាស្ត្ររបស់ព្រះដែលមានបេសកកម្ម។ ក្រុមជំនុំធ្វើសកម្មភាពទៅតាមលក្ខណៈរបស់ខ្លួន។ គឺដូចជាបក្សីដែលហើរ ព្រោះវាជាបក្សី។ ក្រុមជំនុំបំពេញបេសកកម្ម ព្រោះនោះជាក្រុមជំនុំ។

៣. ក្រុមជំនុំ**ចាត់ចែង**អ្វីដែលត្រូវធ្វើ (រចនាសម្ព័ន្ធ/អង្គភាព)

ចុងក្រោយនេះ ក្រុមជំនុំចាត់ចែង និងរៀបចំរចនាសម្ព័ន្ធរបស់ខ្លួនទៅតាមបរិបទ និងយុទ្ធសាស្ត្រការងាររបស់ខ្លួន។ ក្រុមជំនុំផ្តល់បែបផែនទៅដល់តួនាទីរបស់ខ្លួន ដើម្បីសម្រេចកិច្ចការ ដែលក្រុមជំនុំទទួលបេសកកម្មឲ្យបំពេញ។ ក្រុមជំនុំរៀបចំផែនការ ប្រតិបត្តិការណ៍ ការវាយតម្លៃ និងការផ្លាស់ប្តូរ ដោយមានព្រះវិញ្ញាណបរិសុទ្ធដឹកនាំ ដើម្បីសម្រេចទៅតាមបេសកកម្មរបស់ខ្លួន។ គោលការណ៍នៅទីនេះ គឺថានៅពេលដែលក្រុមជំនុំយល់អំពីលក្ខណៈ និងគោលបំណងរបស់ខ្លួន ក្រុមជំនុំនឹងរៀបចំរចនាសម្ព័ន្ធអង្គភាពរបស់ខ្លួន នៅជុំវិញបេសកកម្មរបស់ខ្លួន។

## មូលដ្ឋានគ្រឹះស្របតាមការអនុវត្តន៍

ដានីយ៉ែល សាន់ឆេ (Daniel Sanchez) បានជូននូវហេតុផលយុទ្ធសាស្ត្រជាច្រើន សម្រាប់ការដាំក្រុមជំនុំ ព្រមទាំងបានបង្ហាញជូនផងដែរនូវការជំទាស់រួមមួយចំនួន។ ហេតុផលទាំងនោះត្រូវបានសរុបជូនដូចខាងក្រោម៖

ចូរឲ្យសិក្ខាកាមដាក់ផ្កាយទៅតាមហេតុផល ដែលត្រូវនឹងបរិបទជាក់ស្តែងរបស់ខ្លួន៖

- ☐ ១. **អាត្រាប្រជាជន**កើតឡើងឥតឈប់ឈរ។
- ☐ ២. ក្រុមជំនុំថ្មីឈោងចាប់មនុស្សបាន**ច្រើន**ជាងក្រុមជំនុំដែលមានស្រាប់។
- ☐ ៣. ក្រុមជំនុំដែលបានកើតមក ចង់បង្កើន**ចំនួនសន្ទឹក**។
- ☐ ៤. ក្រុមជំនុំថ្មីជួយលើកកម្លាំងដល់ក្រុមជំនុំដែល**មានស្រាប់**។
- ☐ ៥. ក្រុមជំនុំត្រូវការស្ថិតនៅជិតកន្លែងដែលមានអ្នកបាត់បង់**រស់នៅ**។
- ☐ ៦. ក្រុមជំនុំថ្មីមាន**ភាពរស់រវើក**ច្រើន។
- ☐ ៧. មិនអាចទៅរួចទេ ដែលក្រុមជំនុំមួយឈោងចាប់មនុស្ស**គ្រប់គ្នា**។
- ☐ ៨. ក្រុមជំនុំថ្មីអភិវឌ្ឍ**អ្នកដឹកនាំ**យ៉ាងរហ័ស។
- ☐ ៩. ភាពជា**គ្រួសារតែមួយ**ជួយដល់ភាពជាសិស្ស។

**ការឆ្លុះបញ្ចាំង:**
មកដល់ពេលនេះ តើមានហេតុផលណាមួយសម្រាប់ការដាំក្រុមជំនុំ ដែលលោកអ្នកពុំបានគិតដល់ឬទេ? តើហេតុផលមួយណា ដែលនឹងជំរុញឲ្យមនុស្សដែលលោកអ្នកធ្វើការជាមួយ ដើម្បីដាំក្រុមជំនុំ?

## ការជំទាស់ទូទៅមួយចំនួន:

ចូរសុំឲ្យសិក្ខាកាមដាក់ផ្កាយទៅតាមការជំទាស់ដែលពួកគេបានគិត ឬក៏មានអ្នកបង្ហាញប្រាប់ពួកគេកាលពីមុន:

- ☐ ១. ការចាប់ផ្ដើមក្រុមជំនុំថ្មី ធ្វើឲ្យក្រុមជំនុំដែលមានស្រាប់ចុះខ្សោយ។
- ☐ ២. ការចាប់ផ្ដើមក្រុមជំនុំថ្មី ចំណាយថ្លៃណាស់។
- ☐ ៣. យើងអាចបាត់បង់មនុស្សច្រើន។
- ☐ ៤. យើងកំពុងមានសេចក្ដីត្រូវការចាំបាច់ច្រើនស្រាប់ហើយ។
- ☐ ៥. យើងមិនអាចបង្ខំការដាំក្រុមជំនុំបានទេ។
- ☐ ៦. យើងនឹងមិនអាចរក្សាគោលលិទ្ធិរបស់យើងបានទេ។
- ☐ ៧. ការដាំក្រុមជំនុំបង្កើតភាពស្មុគស្មាញខាងនិកាយ។
- ☐ ៨. មានក្រុមជំនុំមួយនៅគ្រប់ក្រុងទាំងអស់ ជាការអនុវត្តន៍នៅក្នុងសញ្ញាថ្មី។
- ☐ ៩. ការចាប់ផ្ដើមក្រុមជំនុំថ្មី នឹងមិនជួយដល់ព័ន្ធកិច្ចរបស់ខ្ញុំទេ។

### ការឆ្លុះបញ្ចាំង:

តើលោកអ្នករៀនបានអ្វីខ្លះនៅក្នុងមេរៀនទីមួយ ដែលជួយលោកអ្នកឲ្យឆ្លើយតបទៅនឹងការជំទាស់ធំៗទាំងនេះ?

## និមិត្តសម្រាប់ការដាំក្រុមជំនុំ

ហេតុអ្វីបានជាការដាំក្រុមជំនុំថ្មីមានសារសំខាន់? លោកស្ទួត មើរី (Stuart Murry) បានសរុបសេចក្តីអំពីសារសំខាន់នេះយ៉ាងល្អ នៅពេលដែលលោកថ្លែងថា៖

*«មិនថាការលូតលាស់របស់ក្រុមជំនុំ ឬការដាំក្រុមជំនុំទេ នេះជាគោលដៅចុងក្រោយ។ ទាំងពីរនេះស្ថិតនៅក្រោមគោលការណ៍ទេវសាស្ត្រនៃការពង្រីកព្រះរាជ្យរបស់ព្រះ។ ជាញឹកញាប់ ការដាំក្រុមជំនុំធ្វើឲ្យព្រះរាជ្យរីកចម្រើនតាមរបៀបដ៏អស្ចារ្យៈ មានការបង្កើតសហគមន៍នៃជំនឿដែលបង្កើតតម្លៃ និងដំណើរជីវិតក្នុងព្រះរាជ្យតាមរបៀបថ្មី និងនៅកន្លែងថ្មី ដោយប្រកាសដំណឹងល្អដ៏បរិសុទ្ធ ធ្វើជាអំបិល និងពន្លឺនៅក្នុងសង្គម នាំយកទស្សនវិស័យបែបទំនាយមកកាន់បរិបទជីវិត ប្រឈមនឹងសេចក្តីអយុត្តិធម៌ ទំនុកបម្រុងអ្នកក្រ និងអ្នកដែលត្រូវគេកៀបសង្កត់ ធ្វើការជាមួយអ្នកដទៃទៀតស្តារជីវិតបាក់បែក ហើយសហការណ៍ក្នុងការប្រោសមនុស្ស និងសហគមន៍ឲ្យបានជាសះស្បើយ។ ការដាំក្រុមជំនុំបែបនេះ ជាសញ្ញានៃព្រះរាជ្យរបស់ព្រះ»។*

*- ល្បះដកស្រង់ចេញពី «ការចាក់គ្រឹះ»*

ការដាំក្រុមជំនុំមានសារសំខាន់ណាស់ ពីព្រោះការដាំក្រុមជំនុំបង្កើនការពង្រីកព្រះរាជ្យរបស់ព្រះ។ គោលដៅរបស់យើង គឺព្រះរាជ្យ។ ការដាំក្រុមជំនុំបង្កើតផ្នែកទាំងមូលនៃការរីកលូតលាស់របស់ព្រះរាជ្យ។ ព្រះជាម្ចាស់បានធ្វើការនេះរួចហើយ ហើយទ្រង់អញ្ជើញយើងឲ្យចូលរួម! លោកមើរី (ទំព័រ ៨៦) កត់ត្រាអំពីព្រះយេស៊ូដែលបានមានបន្ទូលថា៖ *«ខ្ញុំនឹងសង់ក្រុមជំនុំរបស់ខ្ញុំ»* ប៉ុន្តែព្រះអង្គបានប្រទាន *«សោចូលទៅកាន់ព្រះរាជ្យ»* ដល់លោកពេត្រុស។ ព្រះគ្រិស្តជាព្រះបន្ទូលដែលយកកំណើតជាសាច់ឈាម ដែលបំផ្លាស់បំប្រែជីវិត និងប្រទានបេសកកម្មដល់យើងឲ្យទៅបង្កើតសិស្ស ដែលប្រមូលផ្តុំគ្នាជាសហគមន៍ជំនឿថ្មីមួយ។ របៀបវារៈរបស់ព្រះជាម្ចាស់សម្រាប់ព្រះរាជ្យ រាប់បញ្ចូលការដាំក្រុមជំនុំ។ ក្រោយមក ព្រះយេស៊ូផ្ទាល់ ព្រះអង្គជាគ្រាប់ពូជផង និងជាអ្នកព្រោះពូជផង។

បំណងប្រាថ្នារបស់ព្រះជាម្ចាស់ គឺមានក្រុមជំនុំដែលមានសុខភាពល្អរាប់ពាន់ត្រូវបានដាំឡើងនៅលើទឹកដីរបស់លោកអ្នក! តើលោកអ្នកនឹងរួមចំណែកក្នុងរបៀបណាមួយដើម្បីធ្វើឲ្យការនេះក្លាយជាការពិតឬទេ?

## កំណត់ត្រា|

មេរៀនទី២|

# តើនរណាខ្លះគួរដាំក្រុមជំនុំ?

## គោលដៅ:

គោលដៅមេរៀននេះ គឺផ្ដល់ជូនជាទម្រង់មូលដ្ឋាននៃចរិតលក្ខណៈមួយចំនួន ដែលអ្នកដាំក្រុមជំនុំដ៏ជោគជ័យគួរអនុវត្ត។ យើងនឹងដៅចំណាំភាពសំខាន់នៃការត្រាស់ហៅ និងអ្វីៗដែលជាប់ពាក់ព័ន្ធអំពីរឿងនេះនៅក្នុងព្រះគម្ពីរ រួចពិភាក្សាអំពីតួនាទីនៃការបណ្ដុះបណ្ដាលជាផ្លូវការ ដែលផ្ទុយទៅនឹងការរៀបចំបែបវិជ្ជាជីវៈ ហើយផ្ដល់ជូនជាមធ្យោបាយមួយសម្រាប់ការវាយតម្លៃផ្ទាល់ខ្លួនរបស់អ្នកដាំក្រុមជំនុំ។

## សេចក្ដីផ្ដើម




## សកម្មភាព:

ឲ្យសិក្ខាកាមធ្វើការជាក្រុមដែលមានគ្នាពីបីទៅបួននាក់ ហើយឲ្យរាយបញ្ជីអំពីចរិតលក្ខណៈដែលចាំបាច់សម្រាប់អ្នកដាំក្រុមជំនុំ។ (នៅចុងបញ្ចប់នៃមេរៀន ចូរប្រៀបធៀបបញ្ជីដែលសិក្ខាកាមបានរៀបរាប់ ជាមួយនឹងបញ្ជីដែលបានផ្ដល់ជូននៅក្នុងមេរៀននេះ)។

**រឿងនិទានអំពីមនុស្សម្នាក់ដែលប្រឹងធ្វើការដើម្បីឲ្យគាត់ក្លាយជាអ្នកមានៈ** មានបុរសក្រម្នាក់បានសួរទៅកាន់អ្នកមានម្នាក់ថា ម្ដេចបានជារកលុយបានច្រើន? អ្នកមាននោះបានឆ្លើយថា មកពីគាត់ខំប្រឹងធ្វើការ។ ដូច្នេះអ្នកក្រនោះបានចេញទៅ និងបានខំប្រឹងធ្វើការកាប់គាស់នៅក្នុងចម្ការរបស់គាត់ដោយចបជីក និងប៉ែល។ ច្រើនខែបានកន្លងផុតទៅ ប៉ុន្តែ អ្នកក្រមិនបានក្លាយជាអ្នកមានទេ។

Go and "Dew" Exactly what Joe "Duz". នេះជាកំណត់ត្រាមួយរបស់អ្នកចាត់ការម្នាក់ផ្ញើទៅឲ្យបុគ្គលិកផ្នែកលក់ពីរនាក់ ដែលបានសិក្សាផ្នែកលក់ ប៉ុន្តែ ហាក់បីដូចជាលក់អ្វីមិនដាច់សោះ។ ចំណែកឯ Joe វិញ ទោះជាគាត់ប្រកបអក្សរមិនត្រូវនៅលើរបាយការណ៍លក់របស់គាត់ ហើយអ្នករួមការងារផ្នែកលក់ជាមួយគ្នាសើចចំអកឲ្យគាត់ក៏ដោយ ក៏គាត់អាចលក់អ្វីៗដាច់ទាំងអស់។

## គំរូផ្ទុយគ្នាពីរ




យោបល់មួយចំនួនតាមចម្លើយខាងក្រោមៈ

ក. **ការសិក្សាផ្លូវការ** | មនុស្សត្រូវប្រឹងធ្វើការ ដើម្បីមាន។

ព័ត៌មានខុស ដោយគ្មានការហ្វឹកហ្វឺនជាផ្លូវការ អាចធ្វើឲ្យមនុស្សមានកំហុសយ៉ាងធ្ងន់។

ខ. **គ្មានការសិក្សាផ្លូវការ** | *ទៅ «ធ្វើ» ឲ្យដូចអ្វីដែលលោកចូ «ធ្វើ»ទៅ។*

ប្រសិនបើយើងពឹងផ្អែកទាំងស្រុងលើមនុស្សដែលបានទទួលការហ្វឹកហ្វឺនជាផ្លូវការ ហើយបានរៀនចប់នៅក្នុងវគ្គសិក្ខាសាលា និងវិទ្យាស្ថានព្រះគម្ពីរ យើងនឹងមិនបានឈោងចាប់មនុស្សទូទៅទេ។ (ដើម្បីធ្វើការជាមួយមនុស្សទាំងអស់នៅក្នុងពិភពលោកនេះ អ្នករៀនចប់វគ្គសិក្ខាសាលា មិនគ្រប់គ្រាន់ល្មមទេ!)




ផ្នែកផ្ទុយគ្នានៃបន្ទាត់វិសាលភាព បង្ហាញយើងឲ្យដឹងអំពីឧបសគ្គ។

### *តើយើងគួររៀបចំឲ្យអ្នកណាដាំក្រុមជំនុំ ហើយយើងរៀបចំពួកគេដូចម្ដេចខ្លះ?*

### គ. ដោះស្រាយស្ថានភាពលំបាកដូចម្ដេច? | មនុស្សសំលៀងកាំបិត។

ប្រឹងធ្វើការ និងដោយឆ្លាតវៃ

- សាស្ដា ១០:១០
- កិច្ចការ ១៨:២៤-២៨

សុំសិក្ខាកាមផ្ដល់ឧទាហរណ៍អំពី

- តើការហ្វឹកហ្វឺនផ្លូវការបានជួយពួកគេដូចម្ដេច?

________________________________________

________________________________________

- អ្វីដែលគេរៀនបាននៅពេលកំពុងធ្វើ «ការងារ»

________________________________________

________________________________________

រឿងនិទានមួយទៀត និយាយអំពីបុរសម្នាក់ដែលតែងតែអង្គុយសម្រាកជានិច្ច នៅពេលដែលគាត់កាប់ដើមអំពៅ។ មានបុរសម្នាក់ទៀត ធ្វើការមិនដែលសម្រាកសោះ បានសួរទៅគាត់អំពីរបៀបដែលគាត់ចាត់ចែងកាប់ដើមអំពៅបានច្រើនជានិច្ច ទោះបីជាគាត់បានសម្រាកគ្រប់ពេល។ គាត់ក៏ពន្យល់ប្រាប់បុរសនោះថា ទោះបីមើលមកគាត់ដូចជាសម្រាកមែន ប៉ុន្តែ គាត់សំលៀងកាំបិតរបស់គាត់ទេ។ អ្វីដែលអ្នកផ្សេងគិតថាបង្ហិនពេលវេលា បានជួយឲ្យគាត់កាន់តែមានប្រសិទ្ធិភាពពិតប្រាកដ។

**បទបង្ហាញអំពីការអនុវត្តន៍ជាក់ស្ដែងសម្រាប់ការហ្វឹកហ្វឺនអ្នកដឹកនាំក្រុមជំនុំ**
រវាងសិក្ខាសាលាមួយថ្ងៃ និងបួនឆ្នាំ គឺមានមូលដ្ឋានពឹងផ្អែកលើទ្រឹស្ដីហ្វឹកហ្វឺនអនុវត្តជាក់ស្ដែង ដែលត្រូវបានគេស្គាល់ថា ការអនុវត្តន៍ជាក់ស្ដែង។

## ជ្រើសរើសអ្នកដឹកនាំក្រុមជំនុំ

ការងារកំណត់អត្តសញ្ញាណ និងទទួលស្គាល់អ្នកដឹកនាំក្រុមដែលមានសក្ដានុពល ទាមទារឲ្យយើងពិចារណាអំពីលក្ខណៈមួយចំនួនខាងវិញ្ញាណ និងស្របតាមព្រះគម្ពីរដែលគួរតែមាននៅក្នុងបេក្ខជនដែលយើងជ្រើសរើស។

ក. **គោលការណ៍អណត្តិបញ្ញាតែមួយ** | អ្នកដឹកនាំក្រុមជំនុំមានការត្រាស់ហៅពីព្រះ:

*«ចូរញែកបាណាបាស និងសុលចេញឲ្យខ្ញុំ សំរាប់ការងារដែលខ្ញុំហៅគេឲ្យធ្វើ»* ***កិច្ចការ ១៣:២***

នៅក្នុងសៀវភៅរបស់លោក ដែលមានចំណងជើង *«តម្រូវការសំខាន់ៗសម្រាប់សេចក្ដីអធិប្បាយមួយដែលមានប្រសិទ្ធភាព»* លោកចេមឌីក្រេម បញ្ជាក់អំពីសេចក្ដីត្រូវការឲ្យមានការត្រាស់របស់ព្រះ សម្រាប់អស់អ្នកដែលមានព័ន្ធកិច្ចផ្សព្វផ្សាយព្រះបន្ទូល។ លោករំឭកយើងអំពីពាក្យពីរ ដែលលោកប៉ុលប្រើនៅក្នុងបទគម្ពីរ ដែលបង្ហាញអំពីគុណសម្បត្តិនៃការត្រាស់ហៅ។ (២កូរិនថូស ៥:១៨-២០ និង ១កូរិនថូស ៤:១-២)។

- **អ្នកចែកចាយ (អយកូណុស)** | លោកអ្នកមិនអាចឲ្យនូវអ្វីដែលលោកអ្នកគ្មាន បានឡើយ។
- **រាជទូត** | តំណាងរបស់ស្ដេច មិនមែនប្រយោជន៍ផ្ទាល់ខ្លួនទេ។

**ចំណុចដែលអ្នកដាំក្រុមជំនុំទទួលខុសត្រូវ:** (Stetzer ស្តេតសឺ) ជាអ្នកដាំក្រុមជំនុំ និងជាអ្នកនិពន្ធស្តេតសឺ (២០០៣) បញ្ជាក់អំពីការទទួលខុសត្រូវរបស់អ្នកដាំក្រុមជំនុំ ជាពិសេសនៅពេលដែលក្រុមជំនុំលើសពីការសុបិន និងក្លាយជាការពិតរួចទៅហើយ។ លោកនិយាយអំពីរបៀបដែលធ្វើឲ្យអ្នកដាំក្រុមជំនុំនឿយហត់ ហើយបានផ្តល់យោបល់ថា អ្នកដាំក្រុមជំនុំគួរផ្តោតតិចជាងដប់ប្រាំម៉ោងក្នុងមួយសប្តាហ៍សម្រាប់ការប្រកាសដំណឹងល្អ។ គេគួរមានពេលដប់ម៉ោងសម្រាប់រៀបចំសេចក្តីអធិប្បាយ និងមេរៀនព្រះគម្ពីរ ដប់ម៉ោងសម្រាប់ការងាររដ្ឋបាល និងដប់ប្រាំម៉ោងសម្រាប់ព័ន្ធកិច្ចគ្រូគង្វាល។ ក្នុងករណីអ្នកដាំក្រុមជំនុំវិសមកាល ស្តេតសឺផ្តល់យោបល់ថា គាត់ត្រូវចំណាយបីម៉ោងរាល់សប្តាហ៍សម្រាប់ប្រកាសដំណឹងល្អ ពីរម៉ោងសម្រាប់រៀបចំសេចក្តីអធិប្បាយ និងមេរៀនព្រះគម្ពីរ ពីរម៉ោងសម្រាប់ការងាររដ្ឋបាល និងបីម៉ោងសម្រាប់ព័ន្ធកិច្ចគ្រូគង្វាល។
មិនថាយើងឯកភាពជាមួយស្តេតសឺ ឬយ៉ាងណានោះទេ សូមកុំភ្លេចអំពីពេលវេលាសម្រាប់គ្រួសារ ពេលវេលាផ្ទាល់ខ្លួន និងការទទួលខុសត្រូវផ្សេងទៀត ហើយលោកអ្នកនឹងគិតឃើញអំពីមូលហេតុដែលអ្នកដាំក្រុមជំនុំទទួលបានការលត់ដំខ្លួន និងមានកម្លាំងអស្ចារ្យសម្រាប់តម្រូវការនៃព័ន្ធកិច្ចរបស់គាត់។

ខ. **បួនចំណុចដែលទាក់ទងនឹងការត្រាស់ហៅរបស់អ្នកដាំក្រុមជំនុំ** | អាទូរ៉ូ រ៉ូបើលសរសេរថា ការត្រាស់ហៅរបស់អ្នកដាំក្រុមជំនុំត្រូវតែ:

១. **មកពីស្ថានសួគ៌:** មកពី<u>ព្រះ</u>

២. **ទទួលបានការគាំទ្រ:** ពីខ្លួនឯង និង<u>មនុស្ស</u>ដទៃទៀត

៣. **ជាក់លាក់:** ចំពោះ<u>សហគមន៍</u>/ព័ន្ធកិច្ចពិសេសមួយ។

៤. **ពេញចិត្ត:** អ្នកដាំក្រុមជំនុំរកបាន<u>ការស្កប់ចិត្ត</u>នៅក្នុងការធ្វើព័ន្ធកិច្ចដែលព្រះបានចង្អុលបង្ហាញគាត់។

## ចរិតលក្ខណៈអ្នកដាំក្រុមជំនុំដ៏មានជោគជ័យ

បណ្ឌិតហ្គារីទីយ៉ាបានដកស្រង់ពីបណ្ឌិតឆាលរីតលី ជាសាស្ត្រាចារ្យនៅក្នុងកម្មវិធីប្រឹក្សាចិត្តសាស្ត្រនៅសកលវិទ្យាល័យប្រទេសឥណ្ឌា ដែលត្រូវបានទទួលស្គាល់ជាអ្នកជំនាញនៅក្នុងការអប់រំ និងការជ្រើសរើសព័ន្ធការី។ រីតលីបានរៀបចំបច្ចេកទេសវាយតម្លៃមួយ ពិចារណាអំពីចរិតលក្ខណៈរបស់អ្នកដាំក្រុមជំនុំដ៏មានឥទ្ធិពល។ ខាងក្រោមនេះជាសេចក្តីសង្ខេបអំពីការសិក្សាស្រាវជ្រាវរបស់លោក។

## អ្នកដាំក្រុមជំនុំដ៏មានជោគជ័យ

### ១. ជាមនុស្សមាននិមិត្ត

អ្នកដាំក្រុមជំនុំដ៏មានប្រសិទ្ធភាព មានសមត្ថភាពមើលឃើញឱកាសចំកណ្តាលស្ថានភាព។ គាត់មើលឃើញរូបភាពច្បាស់អំពីអ្វីដែលអនាគតអាចនឹងទៅជាយ៉ាងណា ហើយអាចចែកចាយប្រាប់អំពីរូបភាពនោះ ដល់អ្នកដែលរួមក្រុមជាមួយគាត់ ឲ្យបានដឹង។ និមិត្តរបស់គាត់សម្រាប់ការដាំក្រុមជំនុំដែលមានសុខភាពល្អ នឹងជួយគាត់ឲ្យស៊ូទ្រាំនៅក្នុងគ្រាលំបាក។

លោកនេហេមាបានមើលឃើញអំពីលទ្ធភាពនៅកណ្តាលភាពខ្ទេចខ្ទាំនៃក្រុងយេរូសាឡិម។

*«ធ្វើដូចម្តេចមិនឲ្យទូលបង្គំមានទឹកមុខព្រួយបាន បើទីក្រុង ជាទីមានផ្នូរខ្មោចរបស់ពួកឰយុកោរបស់ទូលបង្គំនៅតែគ្រាំគ្រា ហើយទ្វារក៏ឆេះអស់ហើយដូច្នេះ»* **នេហេមា ២:៣**

*«បើព្រះករុណាសព្វព្រះទ័យយ៉ាងនេះ ហើយបើទ្រង់អាណិតមេត្តាដល់ទូលបង្គំនោះសូមទ្រង់ចាត់ទូលបង្គំ ឲ្យទៅឯស្រុកយូដា ដល់ទីក្រុង ជាទីមានផ្នូរខ្មោចរបស់ឰយុកោទូលបង្គំ ឲ្យបានសង់ទីក្រុងនោះឡើងវិញចុះ»* **នេហេមា ២:៥**

**គំរូរបស់វ៉ លត៍ ឌីសនី (Walt Disney)**: ពួកគេនិយាយថា ក្រោយពីបានបញ្ចប់ផ្នែកដ៏សំខាន់នៃសួនកម្សាន្តឌីសនី វើល (Disney World) វិស្វករបាននិយាយទៅកាន់ប្រពន្ធរបស់ឌីសនី (ដែលលោកឌីសនីបានស្លាប់បាត់មួយរយៈកាលទៅហើយ) ថា៖ «គួរឲ្យអាម៉ាស់ណាស់ ដែលលោកឌីសនីមិនបានឃើញសួននេះ»។ ប្រពន្ធរបស់លោកឌីសនីបានឆ្លើយថា៖ «គាត់បានឃើញរួចហើយ មុននឹងយើងបានឃើញទៅទៀត»។

គំរូវ៉លត៍ ឌីសនី (Walt Disney)

## ២. ជាមនុស្សចេះជំរុញចិត្តខ្លួនឯង

អ្នកដាំក្រុមជំនុំមានចំណង់ដោយចេតនាចំពោះការងារនេះឯង។ កិច្ចការសម្រាប់អ្នកដាំក្រុមជំនុំ (ស្តេតសឺ Stetzer):

- ប្រកាសដំណឹងល្អ
- រៀបចំសេចក្តីអធិប្បាយ និងមេរៀនព្រះគម្ពីរ
- ការងាររដ្ឋបាល
- ព័ន្ធកិច្ចគ្រូគង្វាល
- គ្រួសារ
- ពេលវេលាផ្ទាល់ខ្លួន
- ការទទួលខុសត្រូវផ្សេងៗ

## ៣. អាចនឹងដាក់អ្នកដទៃឲ្យចូលរួមនៅក្នុងព័ន្ធកិច្ច

អ្នកដាំក្រុមជំនុំដឹងអំពីរបៀបបញ្ចូលអ្នកដទៃមកក្នុងព័ន្ធកិច្ច ដើម្បីឲ្យពួកគេមានអារម្មណ៍ថាមានចំណែកក្នុងព័ន្ធកិច្ចនោះដែរ។ មានមនុស្សចូលរួមនៅក្នុងនិមិត្តអំពីក្រុមជំនុំថ្មី ព្រោះតែអ្នកដាំក្រុមជំនុំធ្វើឲ្យពួកគេមានចំណែកណាមួយត្រឹមត្រូវនៅក្នុងបេសកកម្ម។

*«មានគ្នា២នាក់ នោះវិសេសជាងនៅតែឯង»* (សាស្តា ៤:៩)

**គ្រោះថ្នាក់** | អ្នកដាំក្រុមជំនុំជាច្រើន ច្រើនតែចង់ដាំក្រុមជំនុំតែម្នាក់ឯង។ ពួកគេបានប្រើអ្នកផ្សេង ដូចជាខ្ញុំបម្រើឲ្យសម្រេចសេចក្តីប្រាថ្នារបស់ខ្លួន ហើយមិនព្រមប្រើអំណោយទាន និងទេពកោសល្យដែលព្រះអម្ចាស់បានប្រទានដល់ម្នាក់ៗ ដែលជាកូនរបស់ព្រះអង្គទេ។

**គន្លឹះ** | តាមរយៈការងារជាក្រុម គេនឹងឈរមាំមួននៅក្នុងការងារ ហើយពួកគេនឹងក្រៀកគ្នាទៅវិញទៅមកទាំងនៅពេលល្អ និងពេលអាក្រក់។

## ៤. ឈោងចាប់អ្នកមិនទាន់ជឿ

ដោយព្រោះតែគោលបំណងនៃការដាំក្រុមជំនុំ គឺស្វែងរកអ្នកបាត់បង់ យើងត្រូវស្វែងរកពួកគេឲ្យចំកន្លែង។

- កុំទៅស្ទូចត្រីនៅក្នុងអាងចិញ្ចឹមត្រី (ឬស្រះចិញ្ចឹមត្រី)
- ព្រះយេស៊ូមានបន្ទូលថា៖ *«ខ្ញុំនឹងឲ្យអ្នកធ្វើជាអ្នកនេសាទមនុស្ស» ម៉ាថាយ ៤:១៩; ម៉ាកុស ១:៧; លូកា ៥:១០។*



រូបភាពពន្យល់អំពីបុរសស្ទូចត្រីនៅក្នុងផើងចិញ្ចឹមត្រី៖ ដោយព្រោះគោលបំណងនៃការដាំក្រុមជំនុំ គឺស្វែងរកអ្នកបាត់បង់ ដូច្នេះយើងត្រូវរកពួកគេឲ្យចំកន្លែង ដែលយើងអាចរកពួកគេឃើញ។ យើងមិនត្រូវទៅស្ទូចត្រីនៅក្នុងអណ្តូង គ្រលុកទឹកគត់នោះទេ គឺយើងត្រូវទៅកន្លែងដែល «ត្រី« រស់នៅ។ សំណួរដែលអ្នកដាំក្រុមជំនុំម្នាក់ត្រូវសួរគឺ៖ តើ «ត្រី» ដែលខ្ញុំកំពុងរកនៅឯណា? ចូរចាំថា ក្រុមជំនុំថ្មីត្រូវផ្គត់ផ្គង់ដោយអ្នកជឿថ្មី។ ព្រះយេស៊ូបានមានបន្ទូលទៅកាន់ពួកសិស្សរបស់ព្រះអង្គថា៖ «ខ្ញុំនឹងតាំងអ្នកឲ្យធ្វើជាអ្នកនេសាទមនុស្ស» (ម៉ាថាយ ៤:១៩; ម៉ាកុស ១:៧; លូកា ៥:១០)។

អ្នកដាំក្រុមជំនុំត្រូវយល់អំពីអ្វី ដែលព្រះយេស៊ូបានមានបន្ទូល ហើយអភិវឌ្ឍចរិតលក្ខណៈដ៏សំខាន់នេះ ដើម្បីឲ្យមានប្រសិទ្ធភាព សមស្រប និងចំពេលនៅក្នុងការប្រកាសដំណឹងល្អរបស់ពួកគេ។

## ៥. មានការគាំទ្រពីប្តី/ប្រពន្ធ

អ្នកដាំក្រុមជំនុំដែលបានរៀបការហើយ ត្រូវតែមានការគាំទ្រពីប្តី/ប្រពន្ធរបស់ខ្លួន។ ពួកគេទាំងអស់គ្នាត្រូវមានការឯកភាពគ្នាពាក់ព័ន្ធទៅនឹងការរួមចំណែកនឹងគ្នា។ ទោះបីជាគំរូ និងកម្រិតនៃការគាំទ្រប្រែប្រួលក៏ដោយ ក៏អ្នកទាំងពីរ គឺទាំងអ្នកដាំក្រុមជំនុំ និងប្តី/ប្រពន្ធរបស់ខ្លួន ត្រូវតែប្តូរផ្តាច់ចំពោះព័ន្ធកិច្ចនេះ។

ធ្ងន់ធ្ងរ ប៉ុន្តែ ជាកំហុសកើតឡើងទូទៅៈ

កំហុសធ្ងន់បំផុត ដែលអ្នកដាំក្រុមជំនុំរៀបការហើយអាចមាន គឺការមើលស្រាលភាពសំខាន់នៃការរួមចំណែករបស់ប្តី/ប្រពន្ធនៅក្នុងព័ន្ធកិច្ច។ ការដាំក្រុមជំនុំដ៏ជោគជ័យ មិនអាចកើតឡើងបានឡើយ ប្រសិនបើអាពាហ៍ពិពាហ៍របស់គេបរាជ័យ។ មនុស្សម្នាក់មិនអាចប្រយុទ្ធនៅលើសមរភូមិពីរយ៉ាងយូរ ហើយមិនបរាជ័យសមរភូមិណាមួយនោះឡើយ។ ប្រសិនបើលោកអ្នកបានរៀបការរួច កុំដាំក្រុមជំនុំដោយគ្មានការគាំទ្រពីប្តី/ប្រពន្ធរបស់លោកអ្នកនោះឡើយ។

រួមជាមួយនឹងប្តី/ប្រពន្ធរបស់លោកអ្នក

ក. សួរប្តី/ប្រពន្ធរបស់លោកអ្នកអំពីអារម្មណ៍របស់គេយ៉ាងណាចំពោះការដាំក្រុមជំនុំ អ្វីដែលជាអំណោយទាន និងចំណុចចាប់អារម្មណ៍។ សួរគាត់អំពីអ្វីដែលការដាំក្រុមជំនុំធ្វើឲ្យគាត់មិនសប្បាយចិត្ត ហើយពិភាក្សារកវិធីដោះស្រាយបញ្ហាទាំងនេះ។

ខ. ចូរពិភាក្សាជាមួយប្តី/ប្រពន្ធរបស់លោកអ្នក អំពីអ្វីដែលគាត់នឹងចូលរួមនៅក្នុងការដាំក្រុមជំនុំ និងអំពីរបៀបដែលលោកអ្នកនឹងរក្សាអាពាហ៍ពិពាហ៍របស់លោកអ្នកបាន ទោះជាមានការតម្រូវឲ្យមានព័ន្ធកិច្ចក៏ដោយ។

## ៦. អាចសង់ទំនាក់ទំនងជាមួយអ្នកដទៃ

អ្នកដាំក្រុមជំនុំមានសមត្ថភាពបង្កើតទំនាក់ទំនងដ៏ល្អជាមួយអ្នកដទៃ និងមានឥទ្ធិពលដោយសារអំណោយទានរបស់គាត់នៅក្នុងសង្គម។

អ្នកដាំក្រុមជំនុំមានទំនាក់ទំនងល្អជាមួយៈ

- ក្រុមអ្នកដឹកនាំនៅក្នុងការដាំក្រុមជំនុំ
- អស់អ្នកដែលគាត់ចង់ឈោងចាប់
- អ្នកដឹកនាំសហគមន៍
- មនុស្សនៅក្នុងសហគមន៍
- អ្នកដឹកនាំផ្សេងទៀត

មនុស្សមិនខ្វល់ថាលោកអ្នកចេះប៉ុនណានោះទេ ប៉ុន្តែគេនឹងស្គាល់លោកអ្នក ពេលលោកអ្នកចេះខ្វល់អំពីគេ។

## ៧. ផ្តោតទៅលើការលូតលាស់ដ៏បរិសុទ្ធរបស់ក្រុមជំនុំ

អ្នកដាំក្រុមជំនុំដែលមានសុខភាពល្អ ជឿលើការលូតលាស់ដ៏បរិសុទ្ធរបស់ក្រុមជំនុំ។ អ្នកដាំក្រុមជំនុំមិនស្វែងរកតែការលូតលាស់ខាងបរិមាណប៉ុណ្ណោះទេ តែត្រូវស្វែងរកការលូតលាស់ខាងសាច់ឈាម និងខាងវិញ្ញាណផងដែរ។

- ក្រុមជំនុំត្រូវលូតលាស់ក្នុងផ្នែកខ្លះដូចខាងក្រោម៖

  ១. អ្នកជឿលូតលាស់**<u>ខាងវិញ្ញាណ</u>**
  ២. អ្នកជឿលូតលាស់**<u>ខាងសាច់ឈាម</u>**
  ៣. អ្នកជឿលូតលាស់**<u>ខាងបរិមាណ</u>**

- សារសំខាន់នៃការបន្តតាមថៃទាំ (យ៉ូប ៣៩:១៣-១៧)

  អ្នកដាំក្រុមជំនុំ «ដាំ» ក្រុមជំនុំទៅតាមគ្រប់បរិបទនៃព្រះបន្ទូល គឺគាត់មិនត្រឹមតែប្រកាសដំណឹងល្អ ប៉ុន្តែ គាត់ក៏បង្រៀនអ្នកជឿថ្មីនោះដែរ។ ដូច្នេះ គាត់មិនត្រឹមតែព្រោះព្រះបន្ទូល គាត់ក៏ត្រូវច្រូតយកវិញផងដែរ។

  សត្វអូទ្រីសភ្លេចភាពក្មេងវ័យរបស់ខ្លួនជាយ៉ាងណា អ្នកដាំក្រុមជំនុំល្វីលើ្វក៏មិនបន្តបង្រៀនដល់សិស្សដែលមានតម្រូវការនោះដែរ (យ៉ូប ៣៩:១៣-១៧)

## ៨. ការឆ្លើយតបទៅនឹងសហគមន៍

អ្នកដាំក្រុមជំនុំត្រូវដឹងថាសហគមន៍មានលក្ខណៈដូចម្តេច ហើយណែនាំក្រុមជំនុំឲ្យមានទំនាក់ទំនងទៅនឹងសហគមន៍នោះ។ អ្នកដាំក្រុមជំនុំឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគមន៍។ ការនេះជម្រុញគាត់ឲ្យកាន់តែយល់ច្បាស់ឡើងៗថា សហគមន៍មានលក្ខណៈដូចម្តេច ហើយរបៀបដែលក្រុមជំនុំអាចបម្រើសហគមន៍ដូចម្តេច។ ក្រុមជំនុំដែលរួមចំណែក ហើយផ្តោតទៅលើសេចក្តីត្រូវការរបស់សហគមន៍ នឹងមានភាពទម្លុះទម្លាយកាន់តែខ្លាំងនៅក្នុងសហគមន៍ ហើយមនុស្សនៅក្នុងសហគមន៍នឹងទទួលយកកាន់តែច្រើន។

*«នៅគ្រានោះ មានហ្វូងមនុស្សជាធំណាស់ ហើយគេគ្មានអ្វីបរិភោគ បានជាព្រះយេស៊ូវទ្រង់ហៅពួកសិស្ស មកមានបន្ទូលថា ២ ខ្ញុំមានចិត្តក្តួលអាណិតដល់មនុស្សទាំងអស់នេះណាស់ ពីព្រោះគេបានមកនៅជាមួយនឹងខ្ញុំ ៣ថ្ងៃហើយ តែឥឡូវនេះគ្មានអ្វីបរិភោគទេ»* **ម៉ាកុស ៨:១-២។**

សេចក្តីត្រូវការដែលអាចមានៈ

- បញ្ហាគ្រួសារ/អាពាហ៍ពិពាហ៍
- ការញៀនគ្រឿងស្រវឹង
- ភាពឯកកោ
- ភាពអយុត្តិធម៌
- ភាពអត់ឃ្លាន និងក្រីក្រ
- វិស័យអក្ខរកម្ម
- មានទីលំនៅមិនសមរម្យ
- ភាពអត់ការងារ
- ផ្សេងៗ

**ឆ្លុះបញ្ចាំង:**

ចូររាយបញ្ជីអំពីសេចក្តីត្រូវការដែលលោកអ្នកដឹងដោយផ្ទាល់នៅក្នុងសហគមន៍ដែលលោកអ្នកដាំក្រុមជំនុំ:

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

វិភាគសេចក្តីត្រូវការៈ មួយណាដែលបន្ទាន់បំផុតៈ

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

ទូលសុំព្រះជាម្ចាស់ឲ្យជួយលោកអ្នកសង្កេតមើលសេចក្តីត្រូវការដែលមាន។ អធិស្ឋានសុំព្រះជាម្ចាស់ផ្គត់ផ្គង់ធនធានដល់លោកអ្នក ក្នុងការបម្រើសេចក្តីត្រូវការចាំបាច់។

រាយបញ្ជីអំពីធនធានដែលលោកអ្នកដឹងថាអាចជួយបំពេញសេចក្តីត្រូវការដែលលោកអ្នកបានរាយបញ្ជីៈ

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

## ៩. ប្រើអំណោយទានរបស់អ្នកដទៃ

អ្នកដាំក្រុមជំនុំដ៏ជោគជ័យដឹងរបៀបប្រើប្រាស់អំណោយទានរបស់អ្នកដទៃទៅតាមជ្រុងផ្សេងៗនៃព័ន្ធកិច្ច។ គេលើកទឹកចិត្ត និងឲ្យអ្នកដទៃចូលរួមទៅតាមអំណោយទានរបស់គេ ដើម្បីសម្រេចលទ្ធផលអស្ចារ្យជាច្រើន។

**សកម្មភាពៈ**

ចូររាយបញ្ជីអំពីមនុស្សដែលបានចូលរួមដោយផ្ទាល់នៅក្នុងការដាំក្រុមជំនុំរបស់លោកអ្នក និងអំណោយទានដែលលោកអ្នកបានដឹងៈ

| មនុស្ស | អំណោយទាន |
|---|---|
| | |
| | |
| | |
| | |
| | |
| | |
| | |

តើលោកអ្នកអាចធ្វើការនេះ ឬស្គាល់អំណោយទានរបស់មនុស្សម្នាក់ៗបានដោយងាយស្រួលឬទេ?

នៅក្នុងការដាំក្រុមជំនុំរបស់លោកអ្នក ត្រូវបង្រៀនអំពីអំណោយទានខាងវិញ្ញាណ និងផ្តល់ឱកាសឲ្យពួកគេម្នាក់ៗស្គាល់អំណោយទានរបស់ខ្លួន។

## ១០. រវៀស

អ្នកដាំក្រុមជំនុំដឹងថា អ្វីៗមិនមែនកើតឡើងជានិច្ច ទៅតាមការរំពឹងទុកនោះទេ ហើយនៅពេលដាំសហគមន៍ពួកអ្នកជឿ ក៏ដូច្នោះដែរ គឺមិនមែនកើតឡើងទៅតាមការគ្រោងទុករហូតនោះទេ។ យើងត្រូវចេះធ្វើការផ្លាស់ប្តូរ ទៅតាមស្ថានភាពតម្រូវ។

អនុសាសន៍ពីរ:

១. ធ្វើការជាមួយមនុស្ស តម្រូវឲ្យភាពរវាសរវៃ ព្រោះមនុស្សម្នាក់ៗមានឆន្ទៈខ្លួនឯង គំនិតខ្លួនឯង និងបំណងប្រាថ្នាខ្លួនឯង។

២. អ្នកដាំក្រុមជំនុំ មិនត្រូវបកស្រាយគំនិតរបស់អ្នកដទៃ ថាជាអណ្តិបញ្ហានោះឡើយ ព្រោះគ្រប់គំនិតមិនមែនសុទ្ធតែល្អនោះទេ។ ការមានឆន្ទៈទទួលយកគំនិតរបស់អ្នកដទៃ មិនមែនមានន័យថា ធ្វើតាមតែអ្វីដែលអ្នកដទៃនិយាយ ដោយមិនគិតពិចារណានោះឡើយ។

ការឆ្លុះបញ្ចាំង:

តើលោកអ្នកអាចលើកឧទាហរណ៍អំពីស្ថានភាពថ្មីៗ ដែលតម្រូវឲ្យលោកអ្នកចេះបត់បែនឬទេ? តើលោកអ្នកដោះស្រាយស្ថានភាពនោះដោយរបៀបណា? តើលោកអ្នកចង់ផ្លាស់ប្តូរការឆ្លើយតបរបស់លោកអ្នកដូចម្តេច?

## ១១. រក្សាឲ្យមានការរួបរួមជានិច្ចនៅក្នុងក្រុមជំនុំ

អ្នកដាំក្រុមជំនុំដឹងរបៀបបង្កើតបរិយាកាស និងចន្លោះសម្រាប់ការបង្ហាញភាពប្តូផ្តាច់ និងការប្រកបគ្នា។ គាត់ដឹងរបៀបដោះស្រាយជម្លោះដោយសន្តិវិធី គំរូនៃការអត់ធ្មត់ ស្តាប់ច្បាស់ ហើយគោរពមនុស្សដែលមិនឯកភាពជាមួយនឹងគំនិតរបស់ខ្លួន។

*«...ជារូបកាយតែមួយក្នុងព្រះគ្រីស្ទ ហើយជាអវយវៈដល់គ្នានឹងគ្នាបែបយ៉ាងនោះដែរ»* **រ៉ូម ១២;៥**

អ្នកដាំក្រុមជំនុំមិនត្រឹមតែផ្តោតលើការនាំចៀមថ្មីចូលមកក្នុងហ្វូងប៉ុណ្ណោះទេ គាត់ក៏ត្រូវធ្វើការបង្រួបបង្រួមពួកគេឲ្យទៅជារូបកាយតែមួយ។ ដ្បិតរូបកាយដែលធ្វើការល្អ ជារូបកាយដែលមានអវយវៈរួបរួមគ្នា ភ្ជាប់គ្នាដោយសន្លាក់យល់ដឹងតែមួយ។ ក្រុមជំនុំជារូបកាយរបស់អ្នកជឿគ្រប់រូបដែលតភ្ជាប់គ្នានេះត្រូវការរចនាសម្ព័ន្ធ ហេតុផល និងគោលបំណង ដើម្បីតភ្ជាប់គ្នា ហើយបំពេញព័ន្ធកិច្ច។ កម្លាំងរបស់ក្រុមជំនុំបានមកពីការរួបរួមនៅក្នុងក្រុមជំនុំ។

*ចូរបងប្អូនរួបរួមគ្នាឡើង*
*ព្រោះនេះជាច្បាប់ទីមួយ*
*ចូរមានសាមគ្គីភាពពិតប្រាកដ*
*គ្រប់ពេលវេលាទាំងអស់*
*ព្រោះប្រសិនបើពួកគេកាប់ចាក់គ្នាឯង*
*នោះអ្នកក្រៅនឹងបំផ្លាញពួកគេវិនាសអស់។*
*- ដោយ **ម៉ាទីនហ្វីយ័រ្វ** (Martin Fierro)*

## ១២. បង្ហាញពីនាពប្រែប្រួលទៅតាមបរិបទ:

អ្នកដាំក្រុមជំនុំប្រែប្រួលទៅតាមបរិស្ថានរបស់គាត់ និងទទួលស្គាល់បរិបទថ្មីរបស់គាត់។ គាត់ត្រូវតែជា «សាសន៍រ៉ូមសម្រាប់សាសន៍រ៉ូម សាសន៍ក្រិកសម្រាប់សិស្សក្រិក»។

លោកប៉ូលតម្រូវឲ្យលោកទីតុសទទួលយកការកាត់ស្បែក ដើម្បីកុំឲ្យជនជាតិយូដាអន់ចិត្ត។ អ្នកដាំក្រុមជំនុំដ៏ល្អ សុខចិត្តទុកសញ្ជាតិ វប្បធម៌ និងចំណង់ចំណូលចិត្តរបស់ខ្លួនមួយឡែកសិន ហើយស្វែងយល់ពីមជ្ឈដ្ឋានជុំវិញ និងទទួលយកការផ្លាស់ប្តូរចាំបាច់ ដើម្បីឈោងចាប់អ្នកបាត់បង់ (កាឡាទី ២:៣)

### ត្រីដែលតម្រូវទៅតាមស្ថានភាពជីវិត

*«ដ្បិតខ្ញុំបានរៀនឲ្យមានសេចក្តីសន្តោសក្នុងសណ្ឋានគ្រប់យ៉ាង ខ្ញុំធ្លាប់ទ្រាំឲ្យមានសេចក្តីចង្អៀតចង្អល់ ហើយក៏ធ្លាប់មានសេចក្តីរីករាយដែរ ខ្ញុំធ្លាប់ទាំងឆ្អែតទាំងឃ្លាន ទាំងមានទាំងខ្វះ»* **ភីលីព ៤:១៣។**

**ត្រីដែលតម្រូវទៅតាមស្ថានភាពជីវិត:** មានត្រីមួយប្រភេទដែលអាចរស់នៅបានយូរនៅក្នុងភក់ស្ងួត នៅពេលដែលគ្មានទឹកជាច្រើនខែ។ មានត្រីមួយប្រភេទទៀត អាចផ្លាស់ប្តូរទីកន្លែងពីទន្លេមួយទៅកាន់ទន្លេមួយទៀត។ អ្នកដាំក្រុមជំនុំត្រូវតែមានសមត្ថភាពបត់បែនទៅតាមបរិយាកាសយ៉ាងល្អ។

## ១៣. ការប្រើជំនឿរបស់ពួកគេ

អ្នកដាំក្រុមជំនុំដែលស្របច្បាប់មិនរស់នៅដោយសារការខំប្រឹងរបស់គាត់ទេ គឺដោយសារអំណាចរបស់ព្រះជាម្ចាស់វិញ។ អ្នកដាំក្រុមជំនុំរស់នៅស្តែងចេញពីជំនឿរបស់គាត់ ហើយជឿលើភាពស្មោះត្រង់របស់ព្រះជាម្ចាស់ ក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការគ្រប់បែបយ៉ាង ដើម្បីសម្រេចគោលដៅ។

*«គឺព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលថា មិនមែនដោយឥទ្ធិឫទ្ធិ ឬដោយអំណាចទេ គឺដោយសារវិញ្ញាណរបស់អញវិញ»*
**សាការី ៤:៦**

- អ្នកខ្លះខំប្រឹងច្រូតយ៉ាងនឿយហត់សម្រាប់ព្រះអម្ចាស់ ប៉ុន្តែភ្លេចថាព្រះអម្ចាស់ជាម្ចាស់នៃចម្រូត។
- លទ្ធផលដែលចង់បាន មិនកើតឡើងភ្លាមៗជានិច្ចទេ។ អ្នកដាំក្រុមជំនុំត្រូវមានជំនឿថា ព្រះអម្ចាស់នឹងបង្កើតផល តាមពេលវេលាត្រឹមត្រូវ។

## ចរិតលក្ខណៈផ្សេងទៀត ដែលមិនបានលើកឡើង

ប្រៀបធៀបបញ្ជីដែលលោកអ្នកបានរៀបរាប់ជាមួយនឹងសេចក្តីផ្តើមនៃមេរៀនដែលនិយាយអំពីចរិតលក្ខណៈទាំង១៣ ដែលទើបនឹងរៀបរាប់។ តើមានចរិតលក្ខណៈណាមួយ ដែលមិនទាន់បានលើកឡើងឬទេ?

ចូរអានបញ្ជីអំពីចរិតលក្ខណៈ ហើយលើកឧទាហរណ៍អំពីរបៀបដែលចរិតលក្ខណៈនីមួយៗជាក់លាក់មួយបានបង្ហាញជាភស្តុតាង ឬមិនបានបង្ហាញជាភស្តុតាង នៅក្នុងព័ន្ធកិច្ចរបស់អ្នកដាំក្រុមជំនុំ (កុំប្រើឈ្មោះ!) តើការនោះធ្វើឲ្យមានភាពខុសប្លែកអ្វីឬទេ?

**លំហាត់** | ការវាយតម្លៃខ្លួនឯង

សេចក្តីណែនាំៈ ប្រើប្រាស់ពិន្ទុខាងក្រោម (១-៥) ដាក់ពិន្ទុខ្លួនឯងនៅក្នុងប្រអប់ពិន្ទុ។

១ = អត់សោះ ២ = កម្រ ៣ = មានខ្លះ ៤ = ធម្មតា ៥ = ជានិច្ចកាល

| ចរិតលក្ខណៈ | ពិន្ទុ | គំរូនៅពេលដែលលោកអ្នកបង្ហាញចរិតលក្ខណៈនេះ |
|---|---|---|
| ខ្ញុំអាចមើលឃើញរូបភាពព័ន្ធកិច្ច | | |
| រូបភាពនោះកើតឡើង (និមិត្ត) | | |
| ខ្ញុំជម្រុញចិត្តខ្លួនឯង | | |
| ខ្ញុំឲ្យអ្នកដទៃមានចំណែកក្នុងព័ន្ធកិច្ច | | |
| ខ្ញុំឈោងចាប់អ្នកមិនជឿ | | |
| ខ្ញុំមានការគាំទ្រពីប្តី/ប្រពន្ធ | | |
| ខ្ញុំអាចប្រាស្រ័យទាក់ទងអ្នកដទៃបានល្អ | | |
| ខ្ញុំផ្តោតលើការលូតលាស់របស់ក្រុមជំនុំ | | |
| ខ្ញុំឆ្លើយតបចំពោះសហគមន៍ | | |
| ខ្ញុំប្រើអំណោយទានរបស់អ្នកដទៃ | | |
| ខ្ញុំអាចបត់បែនបាន | | |
| ខ្ញុំរក្សាការរួបរួមនៅក្នុងក្រុមជំនុំ | | |
| ខ្ញុំបង្ហាញឲ្យឃើញពីការកែតម្រូវ | | |
| ខ្ញុំប្រើជំនឿរបស់ខ្ញុំ | | |

**អត្ថបទគន្លឹះ** | ១ធីម៉ូថេ ៣ និង ទីតុស ១

**របៀបប្រើសំណួរនេះ**:

១. ប្រើចម្លើយរបស់លោកអ្នកធ្វើជាចំណុចចាប់ផ្តើមការពិភាក្សាជាមួយមនុស្ស ដែលលោកអ្នកទុកចិត្ត ឧទាហរណ៍ជាឧបជ្ឈា ឬជាអ្នកដឹកនាំនិកាយ ដើម្បីជួយគំនិតលោកអ្នក ប្រសិនបើលោកអ្នកពិតជាមានចំណែកនៅក្នុងការដាំក្រុមជំនុំ។ ចូរសុំឲ្យឧបជ្ឈារបស់លោកអ្នក ជួយវាយតម្លៃលោកអ្នកនៅក្នុងចំណុចទាំងនេះ និងជួយលោកអ្នកឲ្យលូតលាស់នៅក្នុងចំណុចដែលត្រូវចាប់អារម្មណ៍។

២. ជ្រើសរើសចំណុចពីរដែលលោកអ្នកខ្សោយបំផុត ហើយសរសេរជំហានអនុវត្តន៍ពីរ ដែលជួយលោកអ្នកឲ្យលូតលាស់នៅក្នុងចំណុចនីមួយៗ។ ចូរឲ្យប្រាកដថា លោកអ្នកជ្រើសរើសសកម្មភាពដែលជាក់ស្តែង ពិតប្រាកដ ហើយមានពេលកំណត់។ រាយការណ៍ប្រាប់ឧបជ្ឈារបស់លោកអ្នក អំពីសកម្មភាពទាំងនេះ។

## សេចក្តីសង្ខេប

- បទពិសោធន៍របស់អ្នកដាំក្រុមជំនុំជាច្រើន ទាំងអ្នកជោគជ័យ និងអ្នកបរាជ័យ ជួយយើងឲ្យកំណត់បានកាត់តែប្រសើរនូវចរិតលក្ខណៈមួយចំនួន ដែលព្រះជាម្ចាស់ប្រើសម្រាប់ដាំក្រុមជំនុំដែលមានសុខភាពល្អ។
- ចូរចាំថា ការដាំក្រុមជំនុំ ជាកិច្ចការដែលយើងត្រូវពឹងលើព្រះអម្ចាស់ ដែលបានចូលរួមដោយផ្ទាល់។ កិច្ចការនេះ មិនមែនពឹងផ្អែកតែម្យ៉ាងទៅលើអ្នកដាំក្រុមជំនុំ ដែលមានចរិតលក្ខណៈពិតប្រាកដនោះទេ។ លោកប៉ូលមានប្រសាសន៍ថាៈ *«ដូច្នេះ អ្នកដាំ និងអ្នកដែលស្រោចទឹក មិនមែនជាអ្វីទេ គឺមានតែព្រះដែលធ្វើឲ្យដុះប៉ុណ្ណោះទើបសំខាន់។»* (១កូរិនថូស ៣:៧)។ ក្រុមជំនុំអាចដុះឡើងបាន តែកាលណាយើងសហការណ៍ជាមួយព្រះជាម្ចាស់។ ព្រះអង្គនឹងសង់ក្រុមជំនុំរបស់ព្រះអង្គ។ មិនថាលោកអ្នកទទួលបានការហ្វឹកហ្វឺនល្អ និងទទួលបានវាយតម្លៃយ៉ាងរលូនប៉ុនណានោះទេ អ្នកដាំក្រុមជំនុំអាចមិនទទួលបានជោគជ័យនៅក្នុងព័ន្ធកិច្ចរបស់ខ្លួនបានឡើយ ប្រសិនបើព្រះជាម្ចាស់មិនមែនជាសិរសា។ ព្រះជាម្ចាស់ស័ក្តិសមទទួលបានសិរីរុងរឿង និងកិត្តិនាម។

មេរៀនទី៣|

# តើក្រុមជំនុំដែលយើងនឹងបង្កើតនោះមានលក្ខណៈដូចម្តេច?

## គោលដៅ:

គោលដៅមេរៀននេះ គឺពណ៌នាអំពីចរិតលក្ខណៈសំខាន់មួយចំនួននៃក្រុមជំនុំដែលមានសុខភាពល្អ ដែលជាគោលដៅនៃការដាំក្រុមជំនុំ។ ជាបឋម យើងបង្ហាញអំពីចំណុចសំខាន់ប្រាំនៃក្រុមជំនុំដែលមានសុខភាពល្អ ហើយបន្ទាប់មក បង្ហាញអំពីតួនាទីគន្លឹះទាំងប្រាំរបស់ក្រុមជំនុំ ដោយមានការចាប់អារម្មណ៍ជាពិសេសទៅលើប្រភេទនៃភាពជាអ្នកដឹកនាំសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ។

## ចាប់ផ្តើមដោយដឹងពីចុងបញ្ចប់នៅក្នុងគំនិត



- រឿងអ្នកបាញ់ព្រួញ: មនុស្សមួយចំនួនបាញ់ព្រួញរួចទើបទៅគូសរង្វង់ព័ទ្ធជុំវិញនៅកន្លែងដែលវាធ្លាក់។ នៅក្នុងការដាំក្រុមជំនុំ យើងត្រូវតែចាប់ផ្តើមដោយដឹងពីចុងបញ្ចប់នៅក្នុងគំនិត។
- ស្ថាបត្យករ
- វិចិត្រករ

នៅក្នុងការដាំក្រុមជំនុំ សំខាន់ណាស់ក្នុងការចាប់ផ្តើមដោយដឹងពីចុងបញ្ចប់នៅក្នុងគំនិត

- តើយើងកំពុងបាញ់អ្វី?
- តើចុងបញ្ចប់ជាអ្វី ដែលយើងធ្វើការឆ្ពោះទៅរក?
- តើក្រុមជំនុំដែលយើងចង់បង្កើតនោះ មានលក្ខណៈដូចម្តេច?
- តើគ្រឿងផ្សំសំខាន់ៗអ្វីខ្លះ ដែលចាំបាច់សម្រាប់សុខភាព និងការលូតលាស់របស់ក្រុមជំនុំ?
- តើអ្វីបន្ទាប់មកទៀត ដែលជាគំរូបេសកកម្ម និងការរៀបចំដែលអាចបង្ហាញថាមានការចាំបាច់ នៅពេលដែលចាប់ផ្តើមក្រុមជំនុំថ្មី?

**ស្ថាបត្យករ និងវិចិត្រករ:**
នៅក្នុងសៀវភៅ **ចរិតលក្ខណៈទាំងប្រាំពីររបស់មនុស្សដ៏មានឥទ្ធិពលបំផុត** លោកស្ទេវិ កូវ៉េយបញ្ជាក់នៅក្នុងសៀវភៅនេះ អំពីសារសំខាន់នៃការចាប់ផ្តើមគម្រោងដោយគិតពីចុងបញ្ចប់។ មុនពេលវិចិត្រករគូរនៅលើផ្ទាំងគំនូរ គាត់មានការស្រមៃរួចជាស្រេចអំពីទិដ្ឋភាពទាំងមូលដែលគាត់ចង់ចែកចាយដល់អ្នកដទៃ។ គាត់ចាប់ផ្តើមដោយដឹងពីចុងបញ្ចប់នៅក្នុងគំនិត។ ដូចគ្នានេះដែរ អគារចាប់ផ្តើមឡើងជាមួយនឹងប្លង់ដែលស្ថាបត្យករបានគូរប្លង់។ គាត់បានចាប់ផ្តើមដោយដឹងពីចុងបញ្ចប់នៅក្នុងគំនិត។ ក្នុងការដាំក្រុមជំនុំ មានសារសំខាន់ណាស់ដែលត្រូវគិតអំពីអ្វីដែលជាគោលដៅ។ តើមានគោលបំណងអ្វី? តើចុងបញ្ចប់នោះជាអ្វីដែលយើងកំពុងដំណើរការទៅកាន់? តើក្រុមជំនុំដែលយើងចង់ដាំនោះមានលក្ខណៈយ៉ាងដូចម្តេច? តើអ្វីខ្លះជាគ្រឿងផ្សំសំខាន់ៗនៃក្រុមជំនុំដែលលូតលាស់ ហើយមានសុខភាពល្អ?

**សកម្មភាពចាប់ផ្តើម** | «សញ្ញាសំខាន់ៗនៃក្រុមជំនុំដែលមានសុខភាពល្អ»

បំបែកសិក្ខាកាមជាពីរក្រុម។ ឲ្យក្រុមមួយកំណត់ចរិតលក្ខណៈរបស់ក្រុមជំនុំដែលគ្មានសុខភាពល្អ ហើយឲ្យក្រុមមួយទៀត កំណត់ចរិតលក្ខណៈរបស់ក្រុមជំនុំដែលមានសុខភាពល្អ។ ចូរអានបញ្ជីឡើងវិញ។ តើសិក្ខាកាមមានការសង្កេតឃើញអ្វីខ្លះចេញពីការអនុវត្តន៍បែបនេះ?

លោកអ្នកអាចអាននិយមន័យ និងលើកឧទាហរណ៍ចេញពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកអ្នកផ្ទាល់ ប៉ុន្តែ ត្រូវចំណាំថាមេរៀននេះអាចវែងបន្តិច ដូច្នេះ លោកអ្នកមិនត្រូវចំណាយពេលច្រើនពេកទៅលើចំណុចណាមួយឡើយ។

## សញ្ញានៃក្រុមជំនុំដែលមានសុខភាពល្អ

*«ដូច្នេះ អ្នករាល់គ្នាមិនមែនជាអ្នកដទៃ ឬជាអ្នកគ្រាន់តែសំណាក់នៅទៀតទេ គឺជាជាតិតែ១នឹងពួកបរិសុទ្ធ ជាពួកដំណាក់ព្រះវិញ ២០ ដែលបានស្អាងឡើងលើជើងជញ្ជាំងនៃពួកសាវ័ក និងពួកហោរា ហើយព្រះយេស៊ូវគ្រីស្ទនោះឯង ទ្រង់ជាថ្មជ្រុងយ៉ាងឯក ២១ ដែលដោយសារទ្រង់ដំណាក់ទាំងមូលនោះបានផ្គុំភ្ជាប់គ្នា ហើយអ្នករាល់គ្នាក៏បានស្អាងឡើងក្នុងទ្រង់ដែរ សំរាប់ជាលំនៅនៃព្រះដោយនូវព្រះវិញ្ញាណ»* អេភេសូរ ២:១៩-២១។

អ្វីដែលបន្ត គឺជាផែនការបេសកកម្ម និងផែនការរៀបចំដែលជួយអ្នកដាំក្រុមជំនុំចាប់ផ្តើមដោយគិតឃើញពីចុងបញ្ចប់។ រូបភាពបង្ហាញនេះសង្ខេបអំពីធាតុដ៏សំខាន់ទាំងប្រាំរបស់ក្រុមជំនុំដែលមានសុខភាពល្អ និងតួនាទីទាំងប្រាំរបស់ក្រុមជំនុំដែលមានសុខភាពល្អទាំងអស់នៅក្នុងបរិបទជាក់លាក់មួយ។




ក្រុមជំនុំមានសុខភាពល្អ ធ្វើឲ្យមានភាពខុសប្លែកនៅក្នុងសហគមន៍របស់ខ្លួនតាមរយៈការបម្រើអ្នកដទៃក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត។ ក្រុមជំនុំនោះហៅមនុស្សចូលមកកាន់ជីវិតថ្មីក្នុងព្រះគ្រិស្ត ហើយជួយពួកគេឲ្យរស់នៅក្នុងព្រះអង្គ។ ក្រុមជំនុំនីមួយៗមានភាពផ្ទាល់ខ្លួនដាច់ឡែកពីគ្នា ហើយការប្រមូលផ្តុំអំណោយទានដោយឡែកៗ រួមមកជាមួយគ្នា គឺដើម្បីក្លាយជាគ្រួសាររបស់ព្រះដែលលូតលាស់។ ក្រុមជំនុំដែលមានសុខភាពល្អ ទទួលអំណាចពីព្រះវិញ្ញាណបរិសុទ្ធ ក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគមន៍ សម្រាប់ជាសិរីរុងរឿងរបស់ព្រះជាម្ចាស់។

# ធាតុសំខាន់ទាំងប្រាំ

## ១. និមិត្តច្បាស់

**និយមន័យ** | ការមាននិមិត្ត មានន័យថាការសម្លឹងមើលទៅអនាគត ហើយឃើញអ្វីដែលព្រះជាម្ចាស់ចង់ឲ្យធ្វើ តាមរយៈលោកអ្នក ដើម្បីសម្រេចគោលបំណងប្រោសលោះរបស់ព្រះអង្គ។

*«ក្រុមជំនុំមើលឃើញច្បាស់នូវអ្វីដែលព្រះជាម្ចាស់ចង់ឲ្យក្រុមជំនុំមានភាពជាយ៉ាងណា ហើយធ្វើអ្វី ដូច្នេះ រូបកាយរបស់ព្រះគ្រិស្ត ត្រូវបម្រើ ដើម្បីបង្កើតស្ថាព្រះហស្តថ្មីរបស់ព្រះអង្គនៅក្នុងសហគមន៍»។*

**ឆ្លុះបញ្ចាំង** | តើព្រះជាម្ចាស់ចង់ឲ្យក្រុមជំនុំដែលលោកអ្នកកំពុងដាំមានភាពជាយ៉ាងណា ហើយធ្វើអ្វី? ដោយភាពជាអ្នកដឹកនាំរបស់លោកអ្នកក្នុងការដាំក្រុមជំនុំ ចូរសរសេរប្រយោគនិមិត្ត សង្ខេបអំពីអ្វីដែលព្រះជាម្ចាស់ត្រាស់ហៅលោកអ្នកឲ្យមានភាពជាយ៉ាងណា ហើយធ្វើអ្វីក្នុងនាមជាក្រុមជំនុំ។ ប្រើប្រាស់ការនេះ ដើម្បីឲ្យនៅតែផ្តោតនៅក្នុងព័ន្ធកិច្ចរបស់លោកអ្នក។

## ២. ភាពជាអ្នកដឹកនាំដែលទទួលបានសិទ្ធិអំណាច

**និយមន័យ** | អូប្រ៊ី ម៉ាលភើរ (Aubrey Malphurs) ឲ្យនិយមន័យភាពជាអ្នកដឹកនាំតាមរបៀបខាងក្រោមនេះៈ *«អ្នកដឹកនាំគ្រិស្តបរិស័ទ ជាមនុស្សដែលបានប្តូរផ្តាច់ចំពោះព្រះ (ចរិតលក្ខណៈ) ជាអ្នកដែលដឹងថាខ្លួននឹងទៅណា (និមិត្ត) និងជាមនុស្សដែលមានអ្នកដើរតាម (ឥទ្ធិពល)»។* ក្រោយពីបានជ្រើសរើសមនុស្សម្នាក់ឲ្យបម្រើជាអ្នកដាំក្រុមជំនុំ យើងត្រូវពិចារណាអំពីជំហានដ៏ជាក់លាក់នៅក្នុងការអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់អ្នកនោះ។

*«ក្រុមជំនុំ ត្រូវបានបម្រើដោយមនុស្សដែលយល់ពីនិមិត្តរបស់ក្រុមជំនុំ ហើយអាចស្រាយបំភ្លឺនិមិត្តយ៉ាងច្បាស់លាស់ទៅកាន់ក្រុមជំនុំ និងអាចរៀបចំស្ថាប័នទាំងមូល ធ្វើឲ្យនិមិត្តនោះក្លាយជាការពិត»។*

**សេចក្តីណែនាំ** | របៀបដែលលោកប៉ូលអភិវឌ្ឍអ្នកធ្វើការ ២ធីម៉ូថេ ២:២

សម្រាប់លោកប៉ូល ការអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់ក្រុមជំនុំតាមតំបន់នីមួយៗ មានសារសំខាន់ណាស់សម្រាប់ឲ្យមាននិរន្តរភាព។ នេះជាអ្វីដែលលោកបានធ្វើៈ

១. លោកបានប្រគល់ឱកាសជាអ្នកដឹកនាំ។ លោកបានដាក់ការងារឲ្យពួកគេធ្វើ។
២. លោកបានប្តូរផ្តាច់ចំពោះការរៀបចំពួកគេ។
៣. លោកទុកចិត្តលើពួកគេ។

**ការគ្រោះថ្នាក់ពីរ |**

១. រោគសញ្ញាព្រះមែស៊ី

បញ្ហានេះផ្ទុយទៅនឹងអ្វីដែលលោកប៉ូលបានធ្វើ។ ក្នុងកាលដែលគំរូរបស់សាវក ជាយន្តកម្មក្នុងការបង្កើតឲ្យមានអ្នកដឹកនាំ ជំងឺនេះបានដាក់ការបន្ទច់បង្អាក់ដល់ពហុគុណរបស់អ្នកដឹកនាំផងដែរ។ ជំងឺនេះមានលក្ខណៈច្បាស់លាស់ និងងាយស្រួលសម្គាល់ណាស់។ យើងអាចសម្គាល់លក្ខណៈរបស់វាដូចខាងក្រោម៖

ក. គិតថាខ្លួនសំខាន់ណាស់

ឧទាហរណ៍: លោកម៉ូសេ (និក្ខមនំ ១៨:១៣-២៧)

ខ. ជឿថាសេចក្ដីត្រូវការរបស់អ្នកដទៃ មានអទិភាពលើសសេចក្ដីត្រូវការរបស់ខ្លួនជានិច្ច។

តើយើងត្រូវប្រឈមនឹងបញ្ហានេះដូចម្ដេច?

ជំហានទី១ | **ទទួលស្គាល់**បញ្ហា

ជំហានទី២ | **ទទួលយក** តរិយាបថជាអ្នករៀន

ជំហានទី៣ | **ស្វែងរក**កិច្ចការរបស់ព្រះនៅក្នុងយើង

២. អ្នកដាំក្រុមជំនុំដែល «ធ្វើអ្វីៗសព្វគ្រប់ទាំងអស់»

រឿង «រថភ្លើងនៅជ្រលងភ្នំ» បង្ហាញឲ្យឃើញពីគ្រោះថ្នាក់ដែលមាន នៅពេលដែលអ្នកដាំក្រុមជំនុំទទួលយកឯកកម្មសិទ្ធិលើភាពជាអ្នកដាំគ្រប់ចំណុចទាំងអស់ ហើយត្រួតត្រាដោយផ្ទាល់ លើអ្វីៗគ្រប់បែបយ៉ាងដែលកើតឡើងនៅក្នុងក្រុមជំនុំថ្មីដែលបានដាំ។

**ចរិតលក្ខណៈទាំងបួនរបស់អ្នកដឹកនាំដែលស្របតាមព្រះគម្ពីរ |**

បណ្ឌិតដាវីឌ រេមីរេស (David Ramírez) កំណត់រូបភាពសំខាន់បួននៅក្នុងសញ្ញាថ្មី:

**ក. អ្នកដឹកនាំ ជាសាវក** រ៉ូម ១:១-៥ ជាអ្នកដែលព្រះចាត់ទៅឯមនុស្ស ឬកន្លែងដែលមិនទាន់បានឮដំណឹងល្អ។

**ខ. អ្នកដឹកនាំ ជាអ្នកបម្រើ** ម៉ាកុស ១០:៤៥; ភីលីព ១:១ បម្រើដោយបន្ទាបខ្លួន និងដោយសេចក្ដីស្រឡាញ់។

**គ. អ្នកដឹកនាំ ជាអ្នកមាននិមិត្ត** អេភេសូរ ១:១៧ មើលឃើញអ្វីដែលព្រះជាម្ចាស់ចង់ឲ្យធ្វើនៅក្នុងសហគមន៍។

**ឃ. អ្នកដឹកនាំ ជាអ្នកប្រគល់សិទ្ធិអំណាច និងជាអ្នកបំពាក់បំប៉ន**
អេភេសូរ ៤:១១-១២ រៀបចំអ្នកដទៃសម្រាប់ព័ន្ធកិច្ច។

**រថភ្លើងនៅជ្រលងភ្នំ:**
មានអ្នកដាំក្រុមជំនុំម្នាក់មិនដែលទំនេរមួយល្ងាចណាសោះ ព្រោះគាត់នៅក្នុងក្រុមជំនុំគាត់ធ្វើអ្វីគ្រប់បែបយ៉ាងតែខ្លួនឯង និងមិនដែលហ្វឹកហ្វឺន ឬប្រគល់ការងារទៅឲ្យអ្នកដទៃឡើយ។ មិនយូរប៉ុន្មាន គាត់បានសុំសម្រាក និងបានទទួលការសម្រាកនៅល្ងាចថ្ងៃច័ន្ទ។ គាត់បានឡើងទៅកំពូលភ្នំ និងបានអង្គុយលើកៅអីនៅទីនោះ។ សមាជិកក្រុមជំនុំបានឃើញគាត់នៅទីនោះ និងបានឆ្ងល់ថាតើគាត់នៅទីនោះធ្វើអ្វី។ គាត់បានឆ្លើយថា ការមើលរថភ្លើងបរកាត់នាពេលរសៀលជារៀងរាល់សប្ដាហ៍ ធ្វើឲ្យគាត់មានអារម្មណ៍បានប្រសើរឡើង ពីព្រោះរថភ្លើងបានបរទៅមុខ ដោយមិនចាំបាច់មានគាត់ជាអ្នករុញ។ គ្រូគង្វាលដែលមិនហ្វឹកហ្វឺនក្រុមជំនុំឲ្យជួយការងារ នៅចុងបញ្ចប់ គាត់ត្រូវជួបនឹងផលវិបាក។

## ៣. សមាជិកចូលរួមព័ន្ធកិច្ច

*«ក្រុមជំនុំធ្វើការទាំងអស់ដោយប្រើអំណោយទានរបស់គេរៀងៗខ្លួននៅក្នុងក្រុមជំនុំ និងនៅក្នុងសហគមន៍»* **១ពេត្រុស ៤:១០-១១**

**ជំហានជាក់ស្តែងប្រាំ |**

១. រៀបចំការអ្នកដឹកនាំរបស់លោកអ្នក ដើម្បី**ក្រុមជំនុំ**ទាំងមូលមានចលនា។

២. បង្រៀនអំពី**អំណោយទានខាងវិញ្ញាណ** និងភាពជាអ្នកមើលការខុសត្រូវលើ**ទេពកោសល្យ**។

៣. សម្គាល់អំណោយទាន និង**ចំណាប់អារម្មណ៍**របស់អ្នកជឿគ្រប់គ្នានៅក្នុងក្រុមជំនុំ។

៤. ឲ្យសមាជិកគ្រប់គ្នាមានការងារធ្វើនៅក្នុង**ព័ន្ធកិច្ច** ឬផ្នែកនៃ**ការបម្រើ**។

៥. សង្កេតតាមដានថាតើ**គ្រប់ផ្នែក**នៃជីវិតក្រុមជំនុំខុសប្លែកយ៉ាងណា ហើយធ្វើការកែតម្រូវអ្វីៗដែលចាំបាច់។

*«ប្រើព័ន្ធកិច្ចរបស់លោកអ្នកដើម្បីសង់មនុស្ស កុំឲ្យមនុស្សសង់ព័ន្ធកិច្ចរបស់លោកអ្នក» - ជេកឃ្វេលីន ហ៊ីស្លេ (Jacqueline Heasley)*

## ៤. ភាពជាអ្នកមើលការខុសត្រូវលើធនធាន

**និយមន័យ** | ក្រុមជំនុំជំរុញសមាជិករបស់ខ្លួនឲ្យធ្វើជាអ្នកមើលការខុសត្រូវលើទ្រព្យសម្បត្តិរបស់ពួកគេ ធនធានរបស់ពួកគេ និងរបស់របរដែលពួកគេមាន (ពេលវេលា ទេពកោសល្យ និងទ្រព្យសម្បត្តិ) ហើយឲ្យប្រើអំណោយទានទាំងខាងសម្ភារៈ និងថវិកា សម្រេចកិច្ចការនៃព្រះរាជ្យរបស់ព្រះនៅក្នុងក្រុមជំនុំ និងនៅក្នុងសហគមន៍របស់ខ្លួន។

*«ចូរថ្វាយកិត្តិនាម ដល់ព្រះយេហូវ៉ា ដោយទ្រព្យសម្បត្តិ ហើយនឹងផលដំបូង ពីសេចក្តីចំរើនរបស់ឯងទាំងអម្បាលម៉ានចុះ យ៉ាងនោះ អស់ទាំងជង្រុកឯងនឹងបានពេញបរិបូរ ឯងអស់ទាំងធុងឯង នឹងបានទឹកទំពាំងបាយជូរហូរហៀរផង»*
**សុភាសិត ៣:៩-១០**

### តើខ្ញុំត្រូវរកថវិកាដាំក្រុមជំនុំយ៉ាងដូចម្តេច?

នៅពេលដែលយើងដឹងថា ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យដាំក្រុមជំនុំថ្មីមួយ មានសំណួរមួយចោទឡើងគឺ «តើយើងនឹងរកលុយចាប់ផ្តើម ហើយអភិវឌ្ឍក្រុមជំនុំថ្មីដោយរបៀបណា?» មានគោលគំនិតដ៏សំខាន់ពីរ ទាក់ទងទៅនឹងគំនិតនេះ គឺភីលីព ៤:៦-៧; ១១-១៣, ១៩។

១. ទុកចិត្តព្រះជាម្ចាស់។ តើយើងជឿព្រះជាម្ចាស់ឬទេ?

២. ស្កប់ចិត្ត។ ព្រះជាម្ចាស់សន្យាថាផ្គត់ផ្គង់គ្រប់សេចក្ដីត្រូវការ មិនមែនគ្រប់ការចង់បាន ឬចំណូលចិត្តផ្ទាល់ខ្លួនរបស់យើងទេ។

**របៀបរកថវិកាដាំក្រុមជំនុំថ្មី**

១. ការផ្គត់ផ្គង់បានមកពីក្រុមជំនុំមេ
២. ការផ្គត់ផ្គង់បានមកពីនិកាយ បេសកកម្ម ឬអង្គការ
៣. ក្រុមផ្គត់ផ្គង់ពិសេសណាមួយ
៤. ការផ្គត់ផ្គង់បានមកពីវិនិយោគិន មិត្តភក្តិ និងសាច់ញាតិ
៥. ការផ្គត់ផ្គង់បានមកពីការលក់ទ្រព្យសម្បត្តិ
៦. ការផ្គត់ផ្គង់បានមកពីប្រាក់បៀវត្សបន្ទាប់បន្សំនៅក្នុងគ្រួសារ
៧. ព័ន្ធកិច្ចអមជាមួយមុខវិជ្ជាជីវៈ

*«ប្រតិទិន និងសៀវភៅសែកជាឯកសារទេវសាស្ត្រ។ របស់ទាំងនេះប្រាប់ថាយើងជានរណា ហើយយើងថ្វាយបង្គំនរណា» - ប្រាយអែនក្លាត់ (Brian Kluth)*

*«មនុស្សឆ្លងកាត់ការបំផ្លាស់បំប្រែបី: ក្បាល ចិត្ត និងហោប៉ៅ។ អកុសលអ្វី ទាំងបីនេះមិនកើតឡើងក្នុងពេលតែមួយទេ!» - ម៉ាទីនលូធើរ (Martin Luther)*

**ការឆ្លុះបញ្ចាំង** | តើក្រុមជំនុំដែលបានដាំ នឹងផ្គត់ផ្គង់ថវិកាដល់លោកអ្នកដែលកំពុងតែធ្វើការយ៉ាងដូចម្ដេច? តើលោកអ្នកបង្រៀនក្រុមជំនុំយ៉ាងដូចម្ដេចដែរអំពីតង្វាយមួយភាគដប់?

## ៨. ការតភ្ជាប់រវាងអត្ថបទ និងខ្លឹមសារ

**និយមន័យ** | ក្រុមជំនុំដែលមានសុខភាពល្អមានគណនេយ្យភាពចំពោះខ្លឹមសាររបស់ខ្លួន (ទីតាំងភូមិសាស្ត្រ កត្តាសង្គម និងសេដ្ឋកិច្ច វប្បធម៌។ល។) នៅពេលដែលរាជសារដំណឹងល្អនៅក្នុងព្រះយេស៊ូគ្រិស្តមិនផ្លាស់ប្រែ នោះក្រុមជំនុំអនុវត្តវិធីសាស្ត្រសម្រាប់ការចែកចាយ។

*គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្ដាលឲ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ និងការបង្ហាត់ខាងឯសេចក្ដីសុចរិត ដើម្បីឲ្យអ្នកសំណាប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះ សំរាប់នឹងធ្វើការល្អគ្រប់មុខ។*
**២ធីម៉ូថេ ៣:១៦-១៧**

## តួនាទីសំខាន់ទាំងប្រាំ | ក្រុមជំនុំផ្កាយប្រាំ

## ១. ការប្រកាសដំណឹងល្អ

*«ក្រុមជំនុំប្រកាសដំណឹងល្អអំពីព្រះយេស៊ូគ្រិស្តតាមរយៈពាក្យសម្ដី និងការប្រព្រឹត្តិ ហើយអញ្ជើញមនុស្សគ្រប់គ្នាឲ្យក្លាយជាផ្នែកនៃព្រះរាជ្យរបស់ព្រះ»* **កិច្ចការ ១:៨**

*«ព្រះអម្ចាស់ ទ្រង់ក៏បន្ថែមនូវអស់អ្នក ដែលកំពុងតែបានសង្គ្រោះរាល់តែថ្ងៃទៅក្នុងពួកជំនុំថែមទៀត»* **កិច្ចការ ២:៤៧**

- ច្បាប់អេងហ្គល (Engel Scale)
- ប្រតិទិន និងសៀវភៅសែកៈ ឯកសារទាំងនេះប្រាប់ឲ្យយើងដឹងថា ក្រុមជំនុំចាប់អារម្មណ៍ និងប្ដូរផ្ដាច់ពិតប្រាកដចំពោះការប្រកាសដំណឹងល្អឬទេ។

*«មហាបេសកកម្ម មិនមែនជាជម្រើសដែលត្រូវពិចារណានោះទេ តែជាបទបញ្ជាដែលត្រូវអនុវត្តតាម» - ហាត់សាន់ថាយល័រ (បេសកជនទៅប្រទេសចិន)*

## ២. ការបង្កើតសិស្ស

*«ក្រុមជំនុំជួយមនុស្សឲ្យមើលឃើញព្រះជាម្ចាស់កាន់តែច្បាស់ ឲ្យស្គាល់ព្រះហឫទ័យព្រះអង្គសម្រាប់ជីវិតរបស់គេ ហើយបំពាក់បំប៉នគេឲ្យដើរតាមព្រះអង្គគ្រប់ផ្នែកទាំងអស់នៃជីវិត»* **២ពេត្រុស ៣:១៨**

*«អ្នកទាំងនោះក៏នៅតែព្យាយាមក្នុងសេចក្ដីបង្រៀនរបស់ពួកសាវក...»*
**កិច្ចការ ២:៤២**

C ទាំងបួននៃការបង្កើតសិស្សៈ

១. ចរិយាមាយាទ (CONDUCT)
២. ចរិតលក្ខណៈ (CHARACTER)
៣. ខ្លឹមសារនៃដំណឹងល្អ (CONTENT of the Gospel)
៤. ការប្ដូរផ្ដាច់ COMMITMENT

**ច្បាប់អេងហ្គល**
ច្បាប់ទាំងនេះបង្ហាញជំហានដែលមនុស្សតែងតែឈានទៅរកការប្រែចិត្តជឿ និងជំហានបន្ទាប់មកទៀត បង្ហាញអំពីការលូតលាស់ក្នុងនាមជាគ្រិស្តបរិស័ទ។

**ច្បាប់អេងហ្គលៈ ការប្រកាសដំណឹងល្អ**
- ៨ មនុស្សមានការយល់ដឹងខ្លះអំពីទេវៈ
- ៧ មនុស្សដឹងអំពីដំណឹងល្អបន្តិចបន្តួច
- ៦ មនុស្សចាប់ផ្ដើមយល់អំពីចំណុចសំខាន់នៃដំណឹងល្អ
- ៥ មនុស្សចាប់ផ្ដើមយល់អំពីការពាក់ព័ន្ធផ្ទាល់ខ្លួននៅក្នុងដំណឹងល្អ។
- ៤ មនុស្សមានឥរិយាបថវិជ្ជមានចំពោះដំណឹងល្អ។
- ៣ មនុស្សពិចារណាអំពីអ្វីដែលការសម្រេចចិត្តទទួលព្រះគ្រិស្ត តម្រូវឲ្យពួកគេបង់ថ្លៃ
- ២ មនុស្សបោះជំហានតាមជំនឿ
- ១ មនុស្សប្រែចិត្ត និងថ្វាយជីវិតដល់ព្រះយេស៊ូ តាមរយៈជំនឿ

**ច្បាប់អេងហ្គលៈ ការកើតជាថ្មី**
+ ១ មនុស្សវាយតម្លៃការសម្រេចចិត្តដើរតាមព្រះយេស៊ូគ្រិស្តរបស់ខ្លួន
+ ២ មនុស្សត្រូវបានបញ្ចូលមកក្នុងរូបកាយរបស់ព្រះគ្រិស្ត
+ ៣ មនុស្សចាប់ផ្ដើមជីវិតនៃការបង្កើតសិស្ស និងការបម្រើ

ដ្យាក្រាម | ជំនឿមួយផ្នែក និងជំនឿរួមទាំងអស់




ជំនឿមួយផ្នែក




ជំនឿរួមទាំងអស់

**ការឆ្លុះបញ្ចាំង |**

តើផ្នែកណាខ្លះនៃជីវិត ដែលមនុស្សនៅក្នុងក្រុមជំនុំរបស់លោកអ្នក ត្រូវការជំនួយភ្ជាប់ទៅនឹងជំនឿរបស់ពួកគេក្នុងព្រះគ្រិស្ត?

________________________________________

________________________________________

________________________________________

តើលោកអ្នកអាចជួយពួកគេធ្វើការតភ្ជាប់យ៉ាងដូចម្តេច?

________________________________________

________________________________________

________________________________________

**ការឆ្លុះបញ្ចាំង |**

ទស្សនៈអំពីជីវិតៈ និងពិភពលោកនៅក្នុងព្រះគម្ពីរៈ គ្រឹះសម្រាប់ការបង្កើតសិស្ស



នៅពេលដែលយើងដឹងថែមទៀតអំពីព្រះជាម្ចាស់ ពិភពលោក និងខ្លួនយើងតាមរយៈ បទគម្ពីរ យើងទទួលបានការជំរុញចិត្តឲ្យនាំយកគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់យើង មកជាការស្ដាប់បង្គាប់ព្រះជាម្ចាស់។ នេះហើយភាពជាសិស្ស គឺលូតលាស់នៅក្នុង ការស្គាល់ព្រះជាម្ចាស់ ពិភពលោក ខ្លួនយើង និងការរស់នៅជាប្រជារាស្ត្ររបស់ព្រះ ជាម្ចាស់ ក្នុងគ្រប់ស្ថានភាពទាំងអស់។

*«មនុស្សមិនកំណត់អនាគតរបស់គេទេ គេកំណត់ចំណង់ចំណូលចិត្តរបស់គេវិញ ហើយចំណង់ចំណូលចិត្តរបស់គេ កំណត់អនាគតរបស់គេ» - មិនស្គាល់ឈ្មោះ។*

*«អ្នកដែលបង្រៀនគោលលទ្ធិ មុនដំបូង ត្រូវតែបង្រៀនដោយជីវិតរបស់គេ...ពុំនោះទេ ដៃម្ខាងទាញទម្លាក់ ដៃម្ខាងសង់» - ម៉ាថូវ ហេនរី (Matthew Henry)*

## ៣. ការបម្រើ

ក្រុមជំនុំបង្ហាញប្រាប់អំពីសេចក្ដីត្រូវការរបស់មនុស្ស ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត ហើយអញ្ជើញពួកគេឲ្យធ្វើជាសិស្សរបស់ព្រះអង្គ។

*«គេក៏លក់ទ្រព្យសម្បត្តិ និងរបស់គេទាំងប៉ុន្មាន ចែកដល់គ្នាតាមដែលគ្រប់គ្នាត្រូវការ...ហើយបណ្ដាជនទាំងអស់គ្នាក៏រាប់អានគេ»* **កិច្ចការ ២:៤៥,៤៧**

### ទំនាក់ទំនងបីប្រភេទរវាងការបម្រើ និងការប្រកាសដំណឹងល្អ

១. ព័ន្ធកិច្ចជា**លទ្ធផល**នៃការប្រកាសដំណឹងល្អៈ ការប្រែចិត្តជឿដល់ព្រះគ្រិស្ត ធ្វើឲ្យយើងខ្វល់អំពីសេចក្ដីត្រូវការរបស់អ្នកដៃ និងបំពេញសេចក្ដីត្រូវការរបស់ពួកគេ។

២. ព័ន្ធកិច្ចជា**ស្ពាន**សម្រាប់ការប្រកាសដំណឹងល្អៈ ការបម្រើអ្នកដទៃ ជាចំណុចចាប់ផ្ដើម ដែលក្រោយមកធ្វើឲ្យគេចង់ស្ដាប់ដំណឹងល្អ។

៣. ព័ន្ធកិច្ច**អមជាមួយ**ការប្រកាសដំណឹងល្អៈ ក្នុងកាលដែលយើងនិយាយអំពីព្រះគ្រិស្ត យើងក៏បម្រើអ្នកដទៃអមជាមួយដែរ។

*«មានតែជីវិតបម្រើអ្នកដទៃប៉ុណ្ណោះ ទើបជាជីវិតមានប្រយោជន៍»*
*- អាល់បើត អេនស្តេន (Albert Einstein)*

*«គ្មានអ្នកណាមានកំហុសធ្ងន់ជាងអ្នកដែលមិនបានធ្វើអ្វីសោះ ដោយសារតែគាត់អាចធ្វើបានតែបន្តិចបន្តួច»*
*- អេតមូន បើគី (Edmund Burke)*

## ៤. ការប្រកបគ្នា

សមាជិកជួយរំលែកបន្ទុកគ្នាទៅវិញទៅមក បង្ហាញឲ្យឃើញអំពីសេចក្តីស្រឡាញ់ និងសេចក្តីមេត្តាករុណារបស់ព្រះគ្រិស្ត។

*«អ្នកទាំងនោះក៏នៅតែព្យាយាម...ក្នុងសេចក្តីប្រកបគ្នា...ពួកអ្នកដែលជឿទាំងប៉ុន្មាន ក៏នៅជាមួយគ្នា ហើយមានរបស់ទាំងអស់នៅមូលព្រមគ្នា...រាល់តែថ្ងៃ គេនៅតែព្យាយាមក្នុងព្រះវិហារ ដោយមានចិត្តព្រមព្រៀងគ្នា...»* **កិច្ចការ ២:៤២, ៤៤, ៤៦**

**យ៉ូហាន ១៧:២០-២៣** | ការរួបរួមរបស់ក្រុមជំនុំពឹងផ្អែកលើសម្ព័ន្ធភាពរវាងព្រះយេស៊ូ និងព្រះវរបិតា។ ទីបន្ទាល់តែមួយដូចគ្នានេះបន្តក្លាយជាកម្លាំងបេសកកម្មដែលជំរុញក្រុមជំនុំសព្វថ្ងៃនេះ។

**ក្រុមតូច** | ផ្តល់ឱកាសសម្រាប់ការរីកចម្រើនខាងវិញ្ញាណ ការស្វែងរកមិត្តភាព និងការប្រកបគ្នា ការទទួលជំនួន ការបម្រើអ្នកដទៃនៅក្នុងពេលមានសេចក្តីត្រូវការចាំបាច់ ការអធិស្ឋានជាមួយគ្នា និងការទទួលយកការគាំទ្រពីគ្នានៅពេលប្រឈមមុខនឹងស្ថានភាពជីវិត។ ព្រោះនៅសតវត្សទីមួយក្រោយព្រះគ្រិស្ត គ្រិស្តបរិស័ទបានជួបប្រជុំគ្នានៅតាមផ្ទះ។ កិច្ចការ ២:២៤, ៥:៤២, ១០:២២, ១២:១២, កូឡុស ៤:១៥។

**ការដោះស្រាយជម្លោះ** | ជម្លោះជាផ្នែកមួយសាមញ្ញ និងមានពិតប្រាកដនៅក្នុងជីវិត។ គោលដៅមិនមែនគេចចេញពីជម្លោះទាំងអស់នោះទេ (មិនអាចទៅរួចទេ) ប៉ុន្តែ ស្វែងរកមធ្យោបាយពិនិត្យមើលស្ថានភាពឲ្យចំគោលដៅ និងយ៉ាងស្ងាត់ស្ងៀមតាមដែលអាចធ្វើទៅបាន ហើយព្យាយាមចាប់យកដំណោះស្រាយ តាមរយៈការពិភាក្សាដ៏ច្បាស់លាស់ និងមានប្រសិទ្ធភាព។

នៅពេលដែលជម្លោះកើតឡើង:

អធិស្ឋានជាមួយគ្នាសុំការដឹកនាំពីព្រះជាម្ចាស់ឆ្លងកាត់បញ្ហា និងសុំឲ្យព្រះវិញ្ញាណបរិសុទ្ធគ្រប់គ្រងចិត្តរបស់ម្នាក់ៗ។

- ស្តាប់អ្នកដទៃ ហើយត្រូវឲ្យប្រាកដថាលោកអ្នកយល់អំពីគំនិតរបស់គេ។
- កុំសន្មត់ថា លោកអ្នកដឹងអំពីអ្វីទាំងអស់ដែលអ្នកដទៃកំពុងគិត។
- ផ្តោតលើបញ្ហា កុំផ្តោតលើមនុស្ស។
- រកឲ្យឃើញជម្រើសដែលអាចធ្វើបាន និងលទ្ធផលនៃជម្រើសនីមួយៗ។
- ព្យាយាមឲ្យមានការយល់ព្រមរួម (ព្រមព្រៀងទៅលើដំណោះស្រាយជាក់លាក់មួយ ទោះមិនមែនជាជម្រើសទីមួយរបស់មនុស្សគ្រប់គ្នាក៏ដោយ) ជាជាងការយកឈ្នះ/ចាញ់គ្នា។

*«តើការនេះធ្លាប់កើតមានចំពោះលោកអ្នកឬទេ ដែលព្យ៉ាណូចំនួនមួយរយត្រូវបានគេលេងសំឡេងតែមួយដូចគ្នា ក្លាយជាចង្វាក់តែមួយទាំងអស់គ្នា? ការមានសំឡេងតែមួយនេះ មិនមែនដោយព្រោះតែព្យ៉ាណូនីមួយៗទេ គឺដោយព្រោះតែព្យ៉ាណូទាំងអស់ត្រូវបានគេលេងទៅតាមខ្នាតមួយដែលខ្ពស់ជាង។ ដូចគ្នាដែរ អ្នកជឿមួយរយនាក់ស្និទ្ធិស្នាលជាមួយគ្នាតាមរយៈការផ្តោតគំនិតរបស់ខ្លួនទៅលើព្រះគ្រិស្ត ធ្វើឲ្យពួកគេកាន់តែផ្តោតទៅលើការរួបរួមគ្នា ដើម្បីទទួលបានការប្រកបគ្នាដែលកាន់តែអស្ចារ្យ» - អេ ឌុបិលយូ ថូហ្សើ (A.W. Tozer)។*

*«មានការជាច្រើនដែលលោកអ្នកអាចធ្វើតែឯងបាន...ប៉ុន្តែការធ្វើជាគ្រិស្តបរិស័ទម្នាក់មិនដូចការអស់នោះទេ ពីព្រោះសេចក្តីស្រឡាញ់របស់បងប្អូន មិនអាចបំបែកចេញពីសេចក្តីស្រឡាញ់របស់ព្រះបានទេ» វីលៀម ហាម (William Ham)។*

*«មធ្យោបាយមានតែមួយគត់ ដើម្បីស្រឡាញ់អស់អ្នកដែលស្អប់យើង...គឺឈប់ផ្តោតទៅលើបំណងអាក្រក់របស់ពួកគេ ហើយផ្តោតទៅលើរូបអង្គរបស់ព្រះស្ថិតនៅក្នុងពួកគេ ដែលនាំឲ្យយើងស្រឡាញ់ពួកគេ»*

*ចន ខាល់វីន (John Calvin) អ្នកកែទម្រង់នៅសតវត្សទី១៦*

## ៤. ការថ្វាយបង្គំ

- ចាប់ផ្តើមអនុវត្តការអធិស្ឋានផ្ទាល់ខ្លួនជាប់ដោយទៀក
- បង្កើតក្រុមគាំទ្រលោកអ្នកនៅក្នុងសេចក្តីអធិស្ឋាន
- អធិស្ឋានទៀងទាត់ជាមួយអ្នកដឹកនាំក្រុមជំនុំនៅក្នុងក្រុមតូចៗ
- អភិវឌ្ឍព័ន្ធកិច្ចអធិស្ឋាននៅក្នុងក្រុមជំនុំតាមតំបន់របស់លោកអ្នក។

ក្រុមជំនុំជួបប្រជុំគ្នាក្នុងនាមជាគ្រួសាររបស់ព្រះជាម្ចាស់ ដើម្បីជួបជាមួយព្រះវរបិតានៃគ្រួសារ ដោយការថ្វាយបង្គំ ការលន់តួ និងសម្តែងការដឹងគុណ ក៏ដូចជាការប្រគល់ខ្លួនបម្រើ និងអធិស្ឋាន។

*«អ្នកទាំងនោះក៏នៅតែព្យាយាម...ព្រមទាំងការកាច់នំបុ័ង និងសេចក្តីអធិស្ឋានផង...ព្រមទាំងសរសើរដល់ព្រះ...»* **កិច្ចការ ២:៤២, ៤៧** ។

**កំណត់សមាសភាព និងរបៀបរបស់លោកអ្នក** | របៀបថ្វាយបង្គំ

មានកត្តាជាច្រើនដែលប៉ះពាល់ដល់របៀបថ្វាយបង្គំរបស់ក្រុមជំនុំ។ មេរៀននេះជួយយើងឲ្យវិភាគការយល់ដឹងមួយចំនួនរបស់អ្នកដឹកនាំក្រុមជំនុំ។ ចម្លើយនោះមិនខុស មិនត្រូវអ្វីទេ។

គោលបំណងនៃមេរៀនទំព័របន្ទាប់ទៅទៀតនេះ គឺបង្កើតការសន្ទនាល្អៗសម្រាប់ការវាយតម្លៃ និងការធ្វើផែនការ។ ការនេះជួយលោកអ្នកឲ្យវិភាគចំគោលដៅចំពោះរបៀបថ្វាយបង្គំដែលក្រុមជំនុំរបស់លោកអ្នកបានអភិវឌ្ឍន៍ និងចំពោះអ្វីដែលត្រូវរក្សាឲ្យនៅដដែល និងអ្វីដែលលោកអ្នកចង់កែតម្រូវ។

## **ការវិភាគ** | របៀបថ្វាយបង្គំ

| | | | | |
|---|---|---|---|---|
| ផុសចេញដោយឯកឯង | | ការធ្វើផែនការ | | ពិស្តារ |
| 1 | ← 2 | 3 | 4 → | 5 |
| រំជួលចិត្ត | | អារម្មណ៍ | | ស្រគត់ស្រគំ |
| 1 | ← 2 | 3 | 4 → | 5 |
| តិចតួច | | ប្លែកៗគ្នា | | ច្រើន |
| 1 | ← 2 | 3 | 4 → | 5 |
| តិចតួច | | ការចូលរួម | | ច្រើន |
| 1 | ← 2 | 3 | 4 → | 5 |
| តិចតួច | | បច្ចេកវិទ្យា | | ច្រើន |
| 1 | ← 2 | 3 | 4 → | 5 |
| អ្នកមិនជឿ | | សង្កត់ពាក្យ | | អ្នកជឿ |
| 1 | ← 2 | 3 | 4 → | 5 |
| បុរាណ | | តន្ត្រី | | សម័យ |
| 1 | ← 2 | 3 | 4 → | 5 |
| ដោយឆ្លាតវៃ | | សេចក្តីអធិប្បាយ | | ប្រើអារម្មណ៍ |
| 1 | ← 2 | 3 | 4 → | 5 |
| តិចតួច | | ការហៅឡើងមកឈរនៅមុខអាសនា | | ច្រើន |
| 1 | ← 2 | 3 | 4 → | 5 |
| ជាសាធារណៈ | | ឆ្លើយតប | | ផ្ទាល់ខ្លួន |
| 1 | ← 2 | 3 | 4 → | 5 |
| បើកចំហ | | ភ្ញៀវ | | មិនបើកចំហ |
| 1 | ← 2 | 3 | 4 → | 5 |
| រៀងៗខ្លួន | | អ្នកដឹកនាំ | | ជាក្រុម |
| 1 | ← 2 | 3 | 4 → | 5 |
| បែបសាសនា | | ពិធីការ | | ក្រៅផ្លូវការ |
| 1 | ← 2 | 3 | 4 → | 5 |
| សប្បាយ | | បរិយាកាស | | ស្រងូតស្រងាត់ |
| 1 | ← 2 | 3 | 4 → | 5 |

ជាមួយអ្នកដឹកនាំក្រុមជំនុំរបស់លោកអ្នក ចូរវិភាគការថ្វាយបង្គំនៅក្រុមជំនុំរបស់លោកអ្នកមានលក្ខណៈដូចម្តេចខ្លះ។ គោលបំណង គឺស្គាល់ការយល់ដឹងរបស់លោកអ្នក។ មានកត្តាច្រើនដែលជះឥទ្ធិពលដល់របៀបថ្វាយបង្គំ។ នៅទីនេះ ក៏មានខ្លះដែរ ប៉ុន្តែ លោកអ្នកអាចបន្ថែមប្រភេទផ្សេងទៀត យោងទៅតាមស្ថានភាពជាក់ស្តែងរបស់លោកអ្នក។ មេរៀនធ្វើរោគវិនិច្ឆ័យនេះ វាស់ស្ទង់ការយល់ដឹងរបស់សមាជិកម្នាក់ៗ ហើយបម្រើដល់ការបង្កើតការសន្ទនា និងការវាយតម្លៃការថ្វាយបង្គំរបស់លោកអ្នក។ យើងសូមជូនយោបល់ថា មុនដំបូង ត្រូវធ្វើការនេះជាក្រុមតូចៗ ហើយបន្ទាប់មក បង្កើតជាក្រុមធំមធ្យម រួចពិភាក្សាអំពីលទ្ធផល។ សំណួរវាយតម្លៃអាចជួយនាំការសន្ទនារបស់លោកអ្នកៈ

ណែនាំអំពី «ការស្ទង់ជីពចរក្រុមជំនុំរបស់លោកអ្នក» ជាមេរៀនធ្វើរោគវិនិច្ឆ័យសម្រាប់ការប្រើប្រាស់នាពេលអនាគតរបស់សិក្ខាកាម។

តើរបៀបថ្វាយដូចម្តេចដែលស័ក្តិសមនឹងបរិបទរបស់លោកអ្នក?

___

___

___

___

___

តើតន្ត្រីប្រភេទណា បច្ចេកវិទ្យាបែបណា...។ល។ ដែលនឹងជួយមនុស្សឲ្យឆ្លើយតបបានល្អចំពោះព្រះជាម្ចាស់ នៅក្នុងការសរសើរតម្កើង ការលន់តួ ការអរព្រះគុណ និងការទូលសូម?

___

___

___

___

___

*«ការថ្វាយបង្គំជា...*
*– ការថ្វាយរូបកាយទាំងមូលរបស់យើងដល់ព្រះ។*
*– ការយល់ពីភាពបរិសុទ្ធរបស់ព្រះអង្គ។*
*– ការរក្សាគំនិតរបស់យើងជាប់ជាមួយសេចក្តីពិត។*
*– ការបន្សុទ្ធគំនិតដោយសោភណភាពរបស់ព្រះអង្គ។*
*– ជាការបើកចំហចិត្តចំពោះសេចក្តីស្រឡាញ់របស់ព្រះអង្គ។*
*– ជាការស្តាប់បង្គាប់តាមបំណងព្រះហឫទ័យរបស់ព្រះអង្គសម្រាប់ជីវិតរបស់យើង។ ហើយទាំងអស់នេះត្រូវបានបកស្រាយតាមរយៈការសរសើរតម្កើង ដែលជាអារម្មណ៍ស្និទ្ធស្នាលបំផុត ជាថ្នាំពូកែបំផុតសម្រាប់បន្សាបភាពអាត្មានិយម ដែលជាឫសគល់អំពើបាប» - ដោយ វីលែមថិមផល (William Temple)*

*«ការប្រកាសដំណឹងល្អមិនមែនជាគោលដៅចុងក្រោយរបស់ក្រុមជំនុំទេ។ កន្លែងនោះត្រូវតែគ្រប់គ្រងដោយការថ្វាយបង្គំ។ ការប្រកាសដំណឹងល្អ មានតែនៅកន្លែងណាដែលពុំទាន់មានការថ្វាយបង្គំប៉ុណ្ណោះ។»*
*ដោយ ចនផាយភើ (John Piper)*

## កំណត់ត្រា៖

ចាប់ផ្ដើមមេរៀននេះដោយនិយាយរឿងខ្លីអំពីមនុស្សម្នាក់ដែលមិនបានត្រៀមខ្លួន និងទទួលលទ្ធផលបរាជ័យ។ ឧ. មានបុរសម្នាក់ត្រូវដើរឆ្ងាយ ប៉ុន្តែមិនបានយកអាហារ ឬទឹកទៅជាមួយទេ។ តើលោកអ្នកគិតថាមានអ្វីកើតឡើង?

# មេរៀនទី៤ | តើជំហានអ្វីខ្លះដែលយើងត្រូវឈានដើម្បីដាំក្រុមជំនុំមួយ?

## គោលដៅ:

សៀវភៅ*ការដាំក្រុមជំនុំដែលមានសុខភាពល្អ* បង្ហាញអំពីយោបល់របស់អ្នកនិពន្ធដែលប្រកបដោយបទពិសោធន៍ពីរនាក់ ទាក់ទងទៅនឹងជំហានដែលយើងត្រូវឈានដើម្បីចាប់ផ្ដើមក្រុមជំនុំមួយ។ នៅទីនេះ យើងសង្ខេបអំពីជំហានមូលដ្ឋានបំផុតដែលមាននៅក្នុងគំរូសម្រាប់ការដាំក្រុមជំនុំ។ គោលបំណងគឺផ្ដល់ឲ្យអ្នកដាំក្រុមជំនុំមានគំរូមួយ ដើម្បីធ្វើការដឹកនាំក្រុមជំនុំមួយដែលមានសុខភាពល្អ។

## មុនពេលដាំក្រុមជំនុំ

នៅពេលដែលលោកអ្នកស្ដាប់ការពណ៌នាអំពីបែបផែននៃការរៀបចំ ចូរកត់ចំណាំអំពីប្រភេទនៃការរៀបចំដែលលោកអ្នកធ្លាប់មាន ឬធ្លាប់បានធ្វើជាក់ស្ដែង សម្រាប់ព័ន្ធកិច្ចដាំក្រុមជំនុំណាមួយរបស់លោកអ្នកៈ

### ១. ការរៀបចំខាងវិញ្ញាណៈ

- ឧទាហរណ៍ ក្រុមជំនុំអាន់ទីយ៉ូក (កិច្ចការ ១៣:១-៣)
- ការអធិស្ឋាន (ម្នាក់ឯង និងជាមួយអ្នកដទៃ) ការតម ការសិក្សាបទគម្ពីរ
- ក្រុមអធិស្ឋានទូលអង្វរសម្រាប់ទិដ្ឋភាពជាក់ស្ដែងរបស់ក្រុមជំនុំ

________________________________________

________________________________________

________________________________________

________________________________________

### ២. ការរៀបចំតាមវិជ្ជាជីវៈ

- យល់ដឹងអំពីការត្រាស់ហៅចំពោះប្រភេទនៃព័ន្ធកិច្ចនេះ ទាំងជឿជាក់ថាព្រះជាម្ចាស់នឹងប្រទានពរដល់ព័ន្ធកិច្ចនេះ។
- សមត្ថភាពជំរុញចិត្ត និងដាក់អ្នកដទៃឲ្យមានចំណែកក្នុងកិច្ចការព័ន្ធកិច្ច។
- ការហ្វឹកហ្វឺនប្រកាសដំណឹងល្អ អធិប្បាយ បង្រៀន ការគ្រប់គ្រង

________________________________________

________________________________________

________________________________________

### ៣. ការរៀបចំខាងសង្គមវិទ្យា និងមនុស្សវិទ្យា

- ការយល់ដឹងអំពីចរិតលក្ខណៈរបស់សហគមន៍
- ការដឹងជាមុនអំពីធនធាន និងការលំបាករបស់សហគមន៍

### ៤. ការរៀបចំខាងទស្សនៈវិទ្យាៈ

- ដឹងច្បាស់អំពីគោលដៅសម្រាប់ក្រុមជំនុំដែលត្រូវដាំៈ
– អត្តសញ្ញាណរបស់ក្រុមជំនុំជាក្រុមជំនុំរបស់ព្រះយេស៊ូគ្រិស្តនៅក្នុងតំបន់នោះ
– អ្វីដែលក្រុមជំនុំនឹងធ្វើ (ថ្វាយបង្គំ អប់រំ បម្រើ ប្រកាសដំណឹងល្អ… )
– របៀបធ្វើការសម្រេចចិត្ត ហើយលើកឡើងពីចំណុចប្រឈម
– របៀបដែលព័ន្ធកិច្ចទទួលបានស្ថិរភាពខាងថវិកា

### ៥. ការរៀបចំយុទ្ធសាស្ត្រៈ

- រកឲ្យឃើញគំរូណាមួយអំពីការដាំក្រុមជំនុំដែលលោកអ្នកនឹងប្រើ
- រកឲ្យឃើញអំណោយទានរបស់មនុស្ស ក្រុមគោលដៅ ធនធានដែលអាចរកបាន

### ៦. ការរៀបចំអារម្មណ៍ៈ

- អាចលត់ដំខ្លួន និងធ្វើការជ្រើសរើសដោយប្រយ័ត្នប្រយែង
- អាចទទួលយកការរិះគន់ និងរៀនចេញពីការរិះគន់
- ចាប់អារម្មណ៍លើគ្រួសាររបស់មនុស្ស និងសុខភាពរបស់មនុស្ស

## ជំហានប្រាំ ដើម្បីដាំក្រុមជំនុំ

នៅក្នុងវគ្គខាងក្រោមនេះ គ្រូហ្វឹកហ្វឺននឹងណែនាំ អំពីជំហានមូលដ្ឋានដាំក្រុមជំនុំ ព្រមទាំងឲ្យសិក្ខាកាមមានឱកាសពិភាក្សា និងលើកឡើងនូវផែនការផ្តួចផ្តើមដាំក្រុមជំនុំ ដែលផ្អែកលើជំហានទាំងនោះ។




- **ភាពស្រដៀងគ្នារបស់អ្នកដាំក្រុមជំនុំ** | ១កូរិនថូស ៣:៦-៩
- **ភាពស្រដៀងគ្នារបស់អ្នកសង់** | ១កូរិនថូស ៣:៩-១០

### ១. ការប្រកាសដំណឹងល្អ | <u>បង្កើត</u>ការទំនាក់ទំនងថ្មីៗ

តើលោកអ្នកនឹងរកឃើញមនុស្សដែលនឹងក្លាយជាផ្នែកនៃក្រុមជំនុំរបស់លោកអ្នកនៅកន្លែងណា?

______________________________
______________________________
______________________________

តើយុទ្ធសាស្ត្រអ្វី ដែលលោកអ្នកនឹងប្រើ ដើម្បីប្រកាសដំណឹងល្អដល់មនុស្ស?

______________________________
______________________________
______________________________

### ២. ការបង្កើតសិស្ស | <u>រៀបចំ</u>ក្រុមតូចដើម្បីសិក្សាព្រះគម្ពីរ

តើលោកអ្នកនឹងធ្វើឲ្យអ្នកជឿថ្មីក្លាយជាសិស្សដោយរបៀបណា?

______________________________
______________________________
______________________________

តើអ្នកជឿថ្មីត្រូវរៀនអ្វី?

______________________________
______________________________

៣. **សមាជិកភាព** | **អភិវឌ្ឍ**ការប្តូរផ្តាច់សម្រាប់ក្រុមជំនុំតាមតំបន់
តើអ្វីទៅជាដំណើរការបញ្ចូលពួកសិស្សទៅក្នុងក្រុមជំនុំ?

តើអ្វីទៅជាការតម្រូវ និងជាការទទួលខុសត្រូវសម្រាប់សមាជិក?

៤. **ភាពជាអ្នកដឹកនាំ** | **រកឲ្យឃើញ** ហើយអភិវឌ្ឍអ្នកដឹកនាំ
តើលោកអ្នកនឹងរកឃើញអ្នកដឹកនាំថ្មីដោយរបៀបណា?

តើលោកអ្នកនឹងហ្វឹកហ្វឺនអ្នកដឹកនាំថ្មីដោយរបៀបណា?

៥. **ការថ្វាយបង្គំ - ការបម្រើ**| **ចាប់ផ្តើម** ការថ្វាយបង្គំ និងព័ន្ធកិច្ចក្នុងសហគមន៍
តើលោកអ្នកចាប់ផ្តើមកម្មវិធីថ្វាយបង្គំនៅពេលណា និងដោយរបៀបណា?

តើព័ន្ធកិច្ចអ្វីនៅក្នុងសហគមន៍ ដែលលោកអ្នកត្រូវចាប់ផ្តើមមុនគេ?

## គំរូប្រាំបីក្នុងការដាំក្រុមជំនុំ

មានគំរូជាង២២សម្រាប់ដាំក្រុមជំនុំ គំរូនីមួយៗសុទ្ធតែមានគុណសម្បត្តិ និងគុណវិបត្តិរៀងៗខ្លួន។ នៅក្នុងវគ្គនេះ លោកអ្នកនឹងពិនិត្យមើលគំរូប្រាំបី ដែលសាមញ្ញបំផុត។

ប្រហែលជាគ្មានពេលណែនាំអំពីគំរូទាំងប្រាំបីនៅក្នុងមេរៀននេះទេ។ ប្រសិនបើមានករណីនេះមែន សូមជ្រើសរើសគំរូបីដែលស័ក្តិសមបំផុតទៅតាមបរិបទរបស់លោកអ្នក ដើម្បីបង្ហាញដល់ក្រុម ហើយពន្យល់គំរូទាំងនោះឲ្យបានល្អ ដោយជួយជាឱវាទផ្សេងៗ ប្រសិនបើលោកអ្នកចង់។ លោកអ្នកក៏អាចបំបែកសិក្ខាកាមជា៨ក្រុម ដោយឲ្យក្រុមនីមួយៗអានគំរូមួយ ហើយធ្វើបទបង្ហាញគំរូនោះប្រាប់ក្រុមទាំងមូល។ មានគំរូច្រើនទៀតដែលបានពណ៌នា និងបង្ហាញនៅគេហទំព័រ www.multiplicationnetwork.org

### ១. គំរូអ្នកផ្តួចផ្តើមបែបឯករាជ្យ |




នៅក្នុងគំរូនេះ ក្រុមជំនុំចាប់ផ្តើមនៅកន្លែងមួយដែលពុំទាន់បានឮដំណឹងល្អពីមុន។ ក្រុមជំនុំចាប់ផ្តើមដោយអ្នកដាំក្រុមជំនុំ ដែលមិនបានទទួលការឧបត្ថម្ភពីស្ថាប័នណាមួយទេ (ឧទាហរណ៍ ក្រុមជំនុំមេ ឬនិកាយ)។ នៅពេលដាំក្រុមជំនុំនោះរួចហើយ អ្នកត្រួសត្រាយក៏ស្វែងរកកន្លែងថ្មី សម្រាប់ដាំក្រុមជំនុំបន្តទៀត។

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| ក. វិញ្ញាណត្រួសត្រាយផ្លូវរបស់អ្នកដាំក្រុមជំនុំ មានលក្ខណៈចម្លង និងជំរុញចិត្តក្រុមឲ្យប្រឈមនឹងការលំបាក។<br>ខ. មានភាពស្មោះត្រង់ណាស់សម្រាប់អ្នកដាំក្រុមជំនុំ/ស្ថាបនិក និងមនុស្សដែលបានរួមចំណែកនៅក្នុងចិត្តឆេះឆួលរបស់គាត់ ក៏ដូចជាការលះបង់របស់គាត់។<br>គ. មានឱកាសច្រើនដើម្បីធ្វើជាអ្នកដឹកនាំ និងការបម្រើ។<br>ឃ. អ្នកត្រួសត្រាយមានសេរីភាពធំធេងក្នុងការសម្រេចចិត្ត ព្រោះគ្មាននរណាម្នាក់មានសិទ្ធិអំណាចលើគាត់ទេ។ | ក. ដោយព្រោះតែគ្មានសិទ្ធិអំណាចនៅលើគាត់ និងគ្មានគណនេយ្យភាពគាត់ខ្វះដំបូន្មាន ដែលអាចជួយការពារគាត់កុំឲ្យមានកំហុស។<br>ខ. ទំនាក់ទំនងគ្រួសាររបស់អ្នកដាំក្រុមជំនុំអាចរឹងស្វួត ពីព្រោះគាត់ធ្វើការយូរ ច្រើនម៉ោង ដោយគ្មានជំនួយពីខាងក្រៅ។<br>គ. ជាញឹកញាប់ ខ្វះខាតប្រភពថវិកាគ្រប់គ្រាន់។<br>ឃ. អ្នកដាំក្រុមជំនុំអាចមានអំនួត និងព្យាយាមបន្តត្រួតត្រាលើសមាជិកទាំងអស់។<br>ង. ខ្វះការគាំទ្រដល់អ្នកដាំក្រុមជំនុំ អាចធ្វើឲ្យមានការបាក់ទឹកចិត្ត ហើយនៅពេលមួយ គាត់ក៏បោះបង់ក្រុមជំនុំដែលបានដាំនោះចោល។ |

## ២. គំរូមេ និង កូន |




នេះជាគំរូយ៉ាងសាមញ្ញដែលត្រូវបានគេប្រើក្នុងការដាំក្រុមជំនុំ។ ក្រុមជំនុំ «មេ» បញ្ជូនគ្រួសារ និងអ្នកដឹកនាំទៅកាន់កន្លែងថ្មីមួយ ហើយផ្តត់ផ្គង់គេទាំងខាងធនធានសេដ្ឋកិច្ច ទាំងការគាំទ្រ។ នេះជាគំរូដ៏ជោគជ័យបំផុត។

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| ក. សមាជិកក្រុមស្ថាបនិក ចាប់ផ្តើមក្រុមជំនុំដោយចែកចាយអំពីទស្សនៈព័ន្ធកិច្ចតែមួយរបស់ក្រុមជំនុំមេ។<br>ខ. មានធនធានគ្រប់គ្រាន់ពីក្រុមជំនុំមេសម្រាប់ឲ្យក្រុមជំនុំកូនចាប់ផ្តើម។<br>គ. ក្រុមជំនុំមេត្រូវអភិវឌ្ឍអ្នកដឹកនាំថ្មី។<br>ឃ. ក្រុមជំនុំមេផ្គត់ផ្គង់ការឧបត្ថម្ភ និងនិមិត្តច្បងជាបន្តទៅដល់អ្នកដាំក្រុមជំនុំ។<br>ង. ពួកគេអាចសម្រេចបានច្រើននៅក្នុងរយៈពេលខ្លី ពីព្រោះពួកគេមានធនធានចាំបាច់។<br>ច. ក្រុមជំនុំដែលបានដាំ តម្រូវឲ្យមានរូបរាងភ្លាមៗ និងមានស្ថិរភាពនៅក្នុងសហគមន៍។ | ក. ត្រូវការធ្វើផែនការច្រើន ការរៀបចំ និងការលះបង់។<br>ខ. អាចនឹងពឹងផ្អែកខ្លាំងពេកទៅលើក្រុមជំនុំមេ។<br>គ. អ្នកដាំក្រុមជំនុំ អាចខំប្រឹងខ្លាំងដូចក្រុមជំនុំមេ (ចម្លងតាម) ហើយមិនបានអភិវឌ្ឍអត្តសញ្ញាណ និងព័ន្ធកិច្ចរបស់ខ្លួន។<br>ឃ. ក្រុមជំនុំមេ អាចជួបការលំបាកដោយព្រោះតែបាត់បង់សមាជិកដែលបានបញ្ជូនទៅកាន់ក្រុមជំនុំកូន។ |

## ៣. គំរូអាណាព្យាបាល |




នេះជាគំរូដូចគ្នាបេះបិទ ទៅនឹងគំរូម្ដាយ-កូន ប៉ុន្តែ ខុសប្លែកគ្នាត្រង់ថា ក្រុមដែលចាប់ផ្ដើមក្រុមជំនុំថ្មីនោះ ប្ដូរទៅកន្លែងមួយឆ្ងាយ ចំណាយលុយកាក់ខ្លួនគេ ស្វែងរកការងារថ្មី ហើយពង្រឹងខ្លួនឯងឲ្យនឹងមាំនៅកន្លែងថ្មីនោះ។

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| ក. ក្រុមនេះមានការប្ដូរផ្ដាច់កម្រិតខ្ពស់សម្រាប់ព្រះគ្រិស្ដ និងសម្រាប់មហាបេសកកម្ម។<br>ខ. សមាជិកក្រុមណាព្យាបាល ថ្វាយផ្ទះរបស់ខ្លួន ដើម្បីចាប់ផ្ដើម។ | ក. ចំនួនមនុស្សនៅពេលចាប់ផ្ដើមមានគ្នាតិចណាស់។<br>ខ. ការឃ្លាតឆ្ងាយពីក្រុមជំនុំមេខាងសាច់ឈាម ធ្វើឲ្យពិបាកក្នុងការទទួលបានការមើលថែគ្រប់គ្រាន់របស់អ្នកដាំក្រុមជំនុំ។ |

## ៤. គំរូក្រុមជំនុំចម្រុះ |




ក្រុមជំនុំនៅតាមទីក្រុង ប្រើប្រាស់អាគារតែមួយក្នុងពេលខុសៗគ្នា សម្រាប់ក្រុមអ្នកជឿផ្សេងៗគ្នា ដោយមានគ្រូគង្វាល និងអ្នកដឹកនាំស្វ័យភាពរបស់ខ្លួន (Anglos, Hispanics, Asians។ល។) ក្រុមនីមួយៗរួមចំណែកខាងថវិកា ដើម្បីថែទាំអាគារ។

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| ក. សេដ្ឋកិច្ចល្អ។<br>ខ. គំរូនេះពង្រីកការប្រើប្រាស់អាគារ និងបរិក្ខា។<br>គ. គំរូនេះមានលក្ខណៈទាក់ទាញខាងដំណឹងល្អ។<br>ឃ. គំរូនេះផ្តល់ជាជម្រើសសម្រាប់ភាសា និងប្រភេទផ្សេងៗនៃកម្មវិធីថ្វាយបង្គំ។<br>ង. គំរូនេះលើកស្ទួយការលុបបំបាត់ការប្រកាន់ពូជសាសន៍។ | ក. ការប្រើប្រាស់អាគារញឹកញាប់ ធ្វើឲ្យចាំចាប់ត្រូវតែមានកាលវិភាគហ្មត់ចត់សម្រាប់កម្មវិធី ដោយបន្សល់នូវកម្រៃតិចតួចសម្រាប់សកម្មភាពខាងក្រៅសកម្មភាពនានាដែលមានហើយ។<br>ខ. ប្រសិនបើក្រុមជំនុំមិនត្រៀមសម្រាប់ការលំបាកដែលកើតចេញពីភាពផ្សេងគ្នាទេ ដូចជាពួកគេគ្មានជំនាញទំនាក់ទំនងល្អ មិនឲ្យតម្លៃមនុស្សលើការផ្សេងៗ ។ល។ នោះអាចមានបញ្ហាច្រើនរវាងក្រុមជំនឿផ្សេងៗគ្នា ដែលនោះជាអ្វីដែលគេពិតជាចង់ចៀសវាង។ |

## ៨. គំរូក្រុមជំនុំរណប |




គំរូនេះ ជាក្រុមជំនុំដែលមានការជួបប្រជុំមួយ មកពីក្រុមជុំនុំពាក់កណ្ដាលឯករាជ្យជាច្រើន។ ក្រុមជំនុំរណប មានទំនាក់ទំនងជិតស្និទ្ធិជាមួយក្រុមជំនុំមេ ទោះបីជាពួកគេមានសេរីភាពកម្រិតណាក៏ដោយ។

| គុណសម្បត្តិ | គុណវិបត្តិ |
| --- | --- |
| ក. គំរូនេះប្រមូលផ្ដុំចរិតលក្ខណៈរបស់ក្រុមជំនុំខ្នាតធំ និងក្រុមកោសិកា។<br>ខ. ផ្ដល់ឱកាសសម្រាប់សិស្សសាលាគម្ពីរទទួលបានបទពិសោធន៍ប្រកាសដំណឹងល្អ និងបង្រៀន។<br>គ. បង្កើតសិស្សបន្ត ការរីកលូតលាស់របស់ក្រុមជំនុំទាំងនេះ មានលក្ខណៈទូលំទូលាយ។ | ក. ការប្រើប្រាស់អចលនៈទ្រព្យដាច់ឡែកពីគ្នា អាចធ្វើឲ្យចំណាយកើនឡើង ដែលត្រូវតែទូរទាត់ឲ្យបានមុនពេល។<br>ខ. តួនាទីរបស់ក្រុមជំនុំមេ និងក្រុមជំនុំរណប អាចច្របូកច្របល់។<br>គ. លោកអ្នកត្រូវកំណត់ឲ្យបាននូវតួនាទីរបស់ក្រុមជំនុំទាំងពីរ ដើម្បីចៀសវាងការបែរចេញ ដែលចាប់ផ្ដើមពីស្វ័យភាព ទៅរកភាពឯករាជ្យពេញទី។ |

## ៦. គំរូក្រុមជំនុំបេសកជន |




នេះជាគំរូស៊ាំបំផុតសម្រាប់ចលនាដំណឹងល្អនៅអាមេរិកខាងជើង។ គ្រូគង្វាលបេសកជន ចាប់ផ្តើមដាំក្រុមជំនុំមួយដោយមានការគាំទ្រពីក្រុមជំនុំច្រើន ដែលមានទីភ្នាក់ងារបេសកកម្មនៅកណ្តាល។ នៅពេលណាដែលក្រុមជំនុំនោះមានរូបរាង មានអាណត្តិគោលលិទ្ធិរបស់ខ្លួន មានអ្នកដឹកនាំ និងមានថវិកា នោះគ្រូគង្វាលក៏លាលែងតំណែង ហើយទុកឲ្យអ្នកដឹកនាំម្នាក់ទទួលបន្ទុក។

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| ក. គំរូនេះដំណើរការល្អនៅក្នុងស្ថានភាពគ្រួសគ្រាយផ្លូវ។<br>ខ. គ្រូគង្វាលបេសកកម្មដែលត្រូវបានចាត់ឲ្យមក ជាទូទៅមានបទពិសោធន៍ល្អ។<br>គ. គ្រូគង្វាល និងគ្រួសាររបស់គាត់ទទួលបានការជួយជ្រោមជ្រែងខាងថវិការឹងមាំ។<br>ឃ. ការជ្រោមជ្រែងខាងថវិកាសម្រាប់ដាំក្រុមជំនុំ អាចបង្កឲ្យពួកគេសង់អាគារបានយ៉ាងឆាប់។ | ក. ការដាំក្រុមជំនុំច្រើនតែពឹងផ្អែកទាំងស្រុងទៅលើធនធានពីភ្នាក់ងារបេសកកម្ម ឬក្រុមជំនុំដែលបានចាត់គ្រូគង្វាលឲ្យមក។<br>ខ. ជានិច្ចកាល គ្រូគង្វាលបេសកជនត្រូវអវត្តមានពីការងារ ដើម្បីរាយការណ៍ទៅឲ្យក្រុមជំនុំដែលបានចាត់ខ្លួន និងដើម្បីរៃប្រាក់ជ្រោមជ្រែងថែមទៀត។<br>គ. ពេលខ្លះ ក្រុមជំនុំបែរជាពឹងផ្អែកលើទីភ្នាក់ងារ ហើយធ្វេសប្រហែសនឹងការទទួលខុសត្រូវចំពោះថវិកាផ្ទាល់ខ្លួន។<br>ឃ.ពិបាកនឹងទទួលជោគជ័យណាស់ក្នុងការបន្តអាណត្តិពីគ្រូគង្វាលបេសកជនស្ថាបនិក ទៅឲ្យគ្រូគង្វាលក្នុងស្រុក ដែលត្រូវនៅជាអចិន្ត្រៃយ៍។ |

## ៧. គំរូក្រុមជំនុំនិកាយ |




នេះជាគំរូប្រភេទសមាគម។ គំរូនេះកើតឡើង នៅពេលដែលក្រុមជំនុំច្រើនរួមគ្នានៅក្នុងកិច្ចសញ្ញាមួយសម្រាប់ចាប់ផ្តើមក្រុមជំនុំ មានធនធានរួម និងចែករំលែកបទពិសោធន៍គ្នា ដើម្បីធ្វើការសិក្សា ជ្រើសរើសតំបន់ ហើយកំណត់គោលដៅសម្រាប់ការដាំក្រុមជំនុំ។

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| ក. ធនធានខាងថវិកាមានកម្រិតខ្ពស់។ រួមគ្នារំលែកបន្ទុកខាងថវិកា។<br>ខ. ការគ្រប់គ្រងមានប្រសិទ្ធភាព។<br>គ. មានបណ្តាញមនុស្សទូលំទូលាយ និងមានគំនិតច្រើន។ | ក. មានលក្ខណៈចង្អៀតសម្រាប់ការចាប់ផ្តើម និងការចូលរួមសកម្មភាពនានាក្នុងស្រុក។<br>ខ. អ្នកដាំក្រុមជំនុំអាចមានអារម្មណ៍ថាខ្លួនត្រូវបានកំណត់ឲ្យធ្វើការ ទៅតាមកម្មវិធី ដែលនិកាយបានដាក់ឲ្យ។<br>គ. អាចបង្កើតឲ្យមាន «ភាពធុញថប់» ប្រសិនបើអ្នកដឹកនាំមិនបានគិតអំពីសេចក្តីត្រូវការនៅតំបន់ដទៃៗទៀត។ |

## ៨. គំរូក្រុមជំនុំកោសិកា |




នេះជារបៀបរៀបចំក្រុមជំនុំដោយប្រើក្រុមតូច និងការជួបប្រជុំគ្នានៅតាមផ្ទះ ជាចំណុចអ័ក្សនៃការងាររបស់ក្រុមជំនុំ។ គំរូនេះរំពឹងចង់បានពហុគុណខាងក្រុមកោសិកា ឯអ្នកដឹកនាំក៏ដូចគ្នានោះដែរ។

| គុណសម្បត្តិ | គុណវិបត្តិ |
| --- | --- |
| ក. លើកស្ទួយដល់ការអភិវឌ្ឍន៍អ្នកដឹកនាំ។<br>ខ. បង្កបរិយាកាសរាប់អានរាក់ទាក់សម្រាប់អ្នកមិនទាន់ជឿ។<br>គ. ផ្ដល់ឱកាសសម្រាប់ការប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់កាន់តែច្រើន។ | ក. ប្រសិនបើការដឹកនាំគ្មានសន្ទុះ គំរូនេះច្រើនតែសម្លាប់ក្រុមជំនុំ ឬក្រុមជំនុំត្រឡប់ជានៅទ្រឹង។<br>ខ. ទាមទារឲ្យមានអ្នកដឹកនាំច្រើនគ្រប់គ្រាន់ ដើម្បីធ្វើតាមគំរូនេះ។<br>គ. បង្កការលំបាកសម្រាប់ពហុគុណដោយព្រោះតែកត្តាសុខស្រួល គឺមនុស្សបានរាប់អានគ្នានៅក្នុងក្រុមរបស់ពួកគេ ហើយមិនចង់ឲ្យបង្កើតឲ្យមានក្រុមថ្មី។ |

**ឆ្លុះបញ្ចាំង:**

- តើគំរូដាំក្រុមជំនុំមួយណា ដែលលោកអ្នកថ្មីកបំផុត?
- តើគំរូដាំក្រុមជំនុំមួយណា ដែលលោកអ្នកកំពុងប្រើនៅក្នុងក្រុមជំនុំ ដែលលោកអ្នកកំពុងដាំបច្ចុប្បន្ននេះ ឬបម្រុងនឹងប្រើ?
- តើលោកអ្នកអាចពង្រីកគុណប្រយោជន៍នៃគំរូនោះយ៉ាងដូចម្ដេច?
- តើលោកអ្នកអាចដោះស្រាយគុណវិបត្តិនៃគំរូនោះយ៉ាងដូចម្ដេច?

## សង្ខេបវគ្គសិក្ខាសាលា

គ្រឿងផ្សំដ៏សំខាន់ទាំងបីៈ

### គណនេយ្យភាព ।

មានការបង្ហាញច្បាស់នៅក្នុងកន្លែងជាច្រើនថា អ្នកដាំក្រុមជំនុំនឹងកាន់តែជោគជ័យ នៅពេលដែលគាត់ដឹងថា ខ្លួនត្រូវរាយការណ៍ប្រាប់អ្នកផ្សេងទៀត តាមរបៀបមួយខ្លី ហើយងាយ។ របាយការណ៍នេះ ត្រូវប្រគល់ទៅឲ្យក្រុមការងាររបស់គាត់ មេក្រុមរបស់គាត់ ឬទីប្រឹក្សាមួយចំនួន ដែលជ្រោមជ្រែងអ្នកដាំក្រុមជំនុំ នៅក្នុងការងាររបស់គាត់។

### ឧបជ្ឈា ।

អ្នកដាំក្រុមជំនុំកាន់តែជោគជ័យ ប្រសិនបើគាត់មានការចូលរួមពីមនុស្សម្នាក់ដែលអាចផ្តល់ការជ្រោមជ្រែងដល់គាត់ ទាំងខាងផ្លូវចិត្ត និងខាងវិញ្ញាណ ព្រមទាំងយកចិត្តទុកដាក់ចំពោះគាត់ និងការងាររបស់គាត់។ ការចុះសួរសុខទុក្ខឲ្យបានញឹកញាប់ អាចប្រែប្រួល ប៉ុន្តែ មិនត្រូវឲ្យតិចជាងម្តងក្នុងមួយខែឡើយ។

### ការជ្រោមជ្រែងពីខាងក្រៅ និងតាមរចនាសម្ព័ន្ធ ।

ការសិក្សាបង្ហាញថា អស់អ្នកដែលមានការទទួលស្គាល់ មានការផ្គត់ផ្គង់ និងអត្ថប្រយោជន៍ពីរចនាសម្ព័ន្ធដែលធំជាងខ្លួន ឬការជ្រោមជ្រែងពីខាងក្រៅ តែងតែទទួលបានគុណប្រយោជន៍ លើសជាងអ្នកដែលធ្វើការម្នាក់ឯង។ នេះមិនមែនសំដៅលើការជ្រោមជ្រែងខាងថវិកាប៉ុណ្ណោះទេ គឺរាប់ទាំងពេលវេលាផងដែរ។

## សិក្ខាសាលាពេលខាងមុខ

ប្រសិនបើលោកអ្នកជាគ្រូគង្វាល ឬជាអ្នកដឹកនាំគ្រិស្តបរិស័ទ ហើយចង់ធ្វើសិក្ខាសាលានៅតាមក្រុមជំនុំក្នុងស្រុករបស់លោកអ្នក ឬចូលរួមក្នុងនាមជាគ្រូហ្វឹកហ្វឺនសិក្ខាសាលា លោកអ្នកអាចធ្វើបានដូចខាងក្រោម៖

១. រៀបចំ និងដឹកនាំវគ្គសិក្ខាសាលារបស់ MNM អាចធ្វើបានដោយប្រើសៀវភៅមេរៀនរបស់អ្នកដឹកនាំ និងរបស់សិក្ខាកាម ដែលអាចទាញយកទៅប្រើបានដោយឥតគិតថ្លៃនៅក្នុងគេហទំព័រ www.multiplicationnetwork.org

២. ទាក់ទងតំណាងរបស់ អង្គការ Multiplication Network និងសុំឲ្យគាត់ជួយលោកអ្នកដឹកនាំវគ្គហ្វឹកហ្វឺនក្នុងក្រុមជំនុំ ឬនៅក្នុងក្រុមរបស់លោកអ្នក។

៣. ក្រោយពីបញ្ចប់វគ្គសិក្ខាសាលា សូមផ្ញើរបាយការណ៍ និងរូបថតក្រុមដែលលោកអ្នកបានហ្វឹកហ្វឺន មកយើងខ្ញុំ។ សូមផ្ញើសេចក្តីសង្ខេបអំពីការវាយតម្លៃ មកយើងខ្ញុំផងដែរ។ គំរូរបាយការណ៍ អាចរកបានយ៉ាងងាយស្រួលនៅលើគេហទំព័រ ឬលោកអ្នកអាចគ្រាន់តែសរសេរផ្ញើមកយើង ដូចខាងក្រោម៖

- របាយការណ៍សាមញ្ញសម្រាប់វគ្គហ្វឹកហ្វឺន។
- វគ្គសិក្ខាសាលា: ការដាំក្រុមជំនុំដែលមានសុខភាពល្អ។
- កាលបរិច្ឆេទ។
- ឈ្មោះក្រុមជំនុំ។
- អាសយដ្ឋានក្រុមជំនុំ។
- ឈ្មោះគ្រូគង្វាល។
- ឈ្មោះអ្នកដែលបានដឹកនាំវគ្គហ្វឹកហ្វឺន។
- ចំនួនសិក្ខាកាម។
- មតិ ឬទីបន្ទាល់ខ្លីៗ។
- សេចក្តីសង្ខេបអំពីការវាយតម្លៃ។

ជានិច្ចកាល យើងស្វែងរកគ្រូហ្វឹកហ្វឺនថ្មីៗ ដើម្បីនឹង**ពហុគុណ**ព័ន្ធកិច្ចនេះ!

ប្រសិនបើលោកអ្នកមានអារម្មណ៍ថា ព្រះអាចប្រើលោកអ្នកតាមរបៀបនេះ សូមទាក់ទងយើង តាមគេហទំព័រ www.multiplicationnetwork.org

## គម្រោងវាយតម្លៃ

១. តើលោកអ្នកឲ្យតម្លៃដូចម្ដេច ចំពោះវគ្គសិក្ខាសាលាស្ដីអំពីការដាំក្រុមជំនុំដែលមានសុខភាពល្អនេះ?
☐ វិសេស ☐ ល្អណាស់ ☐ ល្អ ☐ មធ្យម ☐ អន់

២. តើលោកអ្នកណែនាំវគ្គសិក្ខាសាលានេះដល់អ្នកផ្សេងទៀតឬទេ?
☐ បាទ/ចាំ ☐ ប្រហែល ☐ អាចមិន ☐ មិន

៣. តើលោកអ្នកចង់បន្ថែមអ្វីដល់វគ្គសិក្ខាសាលានេះ?

______________________________

______________________________

______________________________

៤. តើលោកអ្នកចង់ដកអ្វីចេញពីវគ្គសិក្ខាសាលានេះ?

______________________________

______________________________

______________________________

៥. តើលោកអ្នកវាយតម្លៃការរៀបចំរបស់អ្នកដឹកនាំសិក្ខាសាលានេះដូចម្ដេច?
☐ វិសេស ☐ ល្អណាស់ ☐ ល្អ ☐ មធ្យម ☐ អន់

៦. តើដ្យាក្រាម និងស្លាយបញ្ចាំង ជួយលោកអ្នកឲ្យយល់វគ្គមេរៀនទាំងនោះឬទេ?
☐ ច្រើន ☐ ខ្លះ ☐ មិនសូវ ☐ មិនសោះ

៧. គូសរង្វង់លើលេខដែលត្រូវនឹងគំនិតរបស់លោកអ្នកអំពីវគ្គមេរៀនទាំងនោះ

| | តម្លៃខ្ពស់ | | | | តម្លៃទាប |
|---|---|---|---|---|---|
| មេរៀនទី១ \| ហេតុអ្វីត្រូវដាំក្រុមជំនុំដែលមានសុខភាពល្អ? | 5 | 4 | 3 | 2 | 1 |
| មេរៀនទី២ \| តើអ្នកណាត្រូវដាំក្រុមជំនុំ? | 5 | 4 | 3 | 2 | 1 |
| មេរៀនទី៣ \| តើក្រុមជំនុំដែលយើងនឹងដាំឡើងនោះ មានលក្ខណៈ ដូចម្ដេច? | 5 | 4 | 3 | 2 | 1 |
| មេរៀនទី៤ \| ជំហានអ្វីខ្លះដែលយើងត្រូវចាប់ផ្ដើមដាំក្រុមជំនុំមួយ? | 5 | 4 | 3 | 2 | 1 |

៨. មតិ និងគំនិតយោបល់បន្ថែមផ្សេងទៀតៈ

______________________________

______________________________

______________________________

______________________________

______________________________

## កំណត់ត្រា|

multiplication network

*more churches, stronger churches*

# *Certificate of Recognition*

For having satisfactorily completed the workshop

## PLANTING HEALTHY CHURCHES

Sponsored by

Presented to: ____________________

Place: ____________ Date: ____________

*Training Leaders for Church Growth and Church Planting*

www.multiplicationnetwork.org